# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ស.ប.ស.ខ

សមាគមបុគ្គលិកសិក្សាខ្មែរ

* ចំណងមិត្តភាពនិងការឧបត្ថម្ភគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត - សម្ភារៈ

៤៦

# ទស្សនាវដ្ដី គ្រូបង្រៀន




**មហាសន្និបាតអាណត្តិទី១១ (២០១១-២០១៤) នៃសមាគមបុគ្គលិកសិក្សាខ្មែរ**

**ទូទាំងប្រទេស (ខេត្តតាកែវថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៥)**

ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)

# មាតិកា

## គណៈកម្មការរៀបរៀង និងនិពន្ធ

- លោក ជ័យ សយ្យនា
- លោក ថោង បូរ៉ាន់
- លោកស្រី គុយ ផល្លា
- លោកស្រី ប្រាក់ សូលីដា
- លោក ជន ឈាងលី
- លោក ស្វាយ និត្យ
- លោកស្រី អ៊ឹម ប៊ុណ្ណារី
- លោក ព្រុំ សាមិត
- លោកស្រី ចាច់ ធីសារ៉ែន
- លោកស្រី ម៉ក់ ណាង
- លោក ឡៀ សុផន
- លោក អ៊ុំ ដា
- សមាជិកសមាជិកា ស.ប.ស.ខ

## គណៈកម្មការត្រួតពិនិត្យ

- លោក យស់ អ៊ាង
- លោកស្រី ទន់ សាអ៊ឹម
- លោក វ័ត្ត ហួត
- លោក សួង សារុណា
- លោក ស៊ុង វ៉ាន់ថន
- លោក ស៊ិន ស៊ីម

## ការីកុំព្យូទ័រ

- លោក ទេព្វយិន សុវីរៈ

## ក្របខាងក្រៅ

- ពីមុខ: មហាសន្និបាតអាណត្តិទី១១ (២០១១.២០១៤)នៃសមាគមបុគ្គលិកសិក្សាខ្មែរទូទាំងប្រទេស (ខេត្តតាកែវថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៥)

ពីក្រោយ: ភ្នំពេញ រថយន្តឈ្នួលសម្រាប់ដឹកអ្នកដំណើរ


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | ជូនពរឆ្នាំថ្មី | ១ |
| ២ | វិចារណកថា | ២ |
| | **រាជកិច្ច** | |
| ៣ | សេចក្តីសម្រេច | ៣ |
| ៤ | ច្បាប់ស្តីពីការអប់រំ (ត) | ៥ |
| | **វប្បធម៌ទូទៅ** | |
| ៥ | ពាក្យគន្លិះក្នុងការងារផែនការអប់រំ (តចប់) | ៨ |
| ៦ | ប្រភពនៃការអប់រំក្នុងពិភពលោក (ត) | ១០ |
| | **ចិត្តវិទ្យាអប់រំ** | |
| ៧ | អត្តចរិត | ១២ |
| ៨ | មាតាបិតាពុំមែនជាតុលាការ ពុំមែនជាផ្ទាំគុកតែជា អ្នកនាំផ្លូវសម្រាប់បុត្រធីតា (ត) | ១៥ |
| | **ការអប់រំ និងគរុកោសល្យ** | |
| ៩ | របៀប វិធីផ្ទាល់ខ្លួនរបស់គ្រូ ក្នុងការបង្រៀន | ១៧ |
| ១០ | អភិវឌ្ឍរបៀបធ្វើការជាក្រុម (ត) | ១៩ |
| ១១ | របៀបប្រើពាក្យ (ត) | ២១ |
| ១២ | សាលាធនធានជួយបង្កើនគុណភាពអប់រំនៅកម្ពុជា (ត) | ២៣ |
| ១៣ | តាក់តែងប្រធានចំណោទដោយផ្តើមចេញពីព័ត៌មាន និងសំណួរ | ២៥ |
| | **កំណាព្យ និងកម្សាន្ត** | |
| ១៤ | កតញ្ញូតាធម៌ (បទកាកគតិ) (តចប់) | ២៨ |
| ១៥ | ការងារកសិកររដូវវស្សា (បទពាក្យប្រាំពីរ) | ៣០ |
| | **វេទិកាស្វែរិន** | |
| ១៦ | ពុទ្ធសាសនានៅប្រទេសកម្ពុជា (ត) | ៣១ |
| ១៧ | សាលារៀនគឺជាគ្រឹះស្ថានសង្គមមួយ (ត) | ៣៣ |
| | **ព័ត៌មាន** | |
| ១៨ | ប្រព័ន្ធបកតិសំខ្យាខ្មែរ | ៣៦ |
| ១៩ | ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១២ (ត) | ៣៨ |
| ២១ | ដំណឹងមរណភាព | ៤១ |
| ២២ | ស្ថិតិសព ខែឧសភាដល់ខែសីហា ឆ្នាំ២០១៤ | ៤២ |



## ទូរស័ព្ទផ្ទះគ្រូបង្រៀន

ភ្នំពេញ : ០៨៩ ៦៨៤ ០៨១

ព្រះសីហនុ : ០១២ ៦៥៩ ៥៦០

សៀមរាប : ០១២ ៦៧៥ ៦៤០

កំពង់ចាម : ០១១ ៧៤២ ២២៤

ស្វាយរៀង : ០៩៧ ២ ៦៥៥ ៩៨៧

ព្រៃវែង : ០១២ ៦៧១ ៦៤០

កំពត : ០១២ ៨៥៦ ៧២២

កែប : ០៩៧ ៨ ៧២១ ៨៨០

តាកែវ : ០៩៧ ៩ ៧៦១ ៥៨៨

រតនៈគិរី : ០៩៧ ៩ ០៤២ ៥៨៤

ព្រះវិហារ : ០១២ ២១៨ ២៨១

បាត់ដំបង : ០១២ ៦៧៣ ៦៦២




# ជូនពរឆ្នាំថ្មី

## ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំមមែ .សប្តស័ក

## ព.ស.២៥៥៩

## គណៈកម្មាធិការកណ្តាល ស.ប.ស.ខ.

សូមបួងសួងប្រសិទ្ធពរជ័យ សិរីមង្គលវិបុលសុខ មហាប្រសើរ ជូនចំពោះ សមាជិក សមាជិកា នៃសមាគមបុគ្គលិកសិក្សាខ្មែរទូទាំងប្រទេស សូមប្រកបបាន សុខភាពល្អបរិបូណ៌ អាយុយឺនយូរ និងមានពលានុភាពខ្លាំងក្លា ដើម្បីអភិវឌ្ឍ ការងារអប់រំ និងការងារសមាគមឱ្យ បានរីកចម្រើនរុងរឿងតរៀងទៅ ។

ជ.គណៈកម្មាធិការកណ្តាល

ប្រធាន

យស់ អ៊ាង

# វិចារណកថា

កាលពីខែមីនា ឆ្នាំ២០១៥ ក្នុងពេលបំពេញទស្សនកិច្ច លោកប្រធានធនាគារអភិវឌ្ឍន៍អាស៊ី ADB បានវាយតម្លៃជាវិជ្ជមានថា "ស្ថានភាពសេដ្ឋកិច្ចកម្ពុជាមានកំណើនថេរ ជុំវិញអត្រាជាង៧%ប្រចាំឆ្នាំ សម្រាប់រយៈពេលមធ្យមនិងវែង ព្រោះមូលដ្ឋានបង្អែកកាន់តែគ្រប់ជ្រុងជ្រោយ និងទូលំទូលាយពិសេស ការដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម សិប្បកម្ម"។ ទន្ទឹមនឹងនេះគុណភាពអប់រំដែលមានការរួមចំណែកក្នុងកំណើននេះដែរមិនទាន់មានកម្រិតប្រជុំប្រសងជាមួយស្តង់ដាតំបន់និងពិភពលោកនៅឡើយ ពិសេសការកំណត់គោលដៅអភិវឌ្ឍនជំនាញដើម្បីដោះស្រាយភាពមិនទាន់ស្របគ្នា រវាងជំនាញនៃអ្នកមានសញ្ញាប័ត្រ និងជំនាញរបស់វិស័យឧស្សាហកម្ម សិប្បកម្ម។ ក្នុងន័យនេះ គោលដៅអភិវឌ្ឍនជំនាញត្រូវតែរៀបចំអនុវត្តនៅភូមិសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិដោយយកចិត្តទុកដាក់ជំរុញ និងបង្កលក្ខណៈចំពោះសិស្សដែលមានឧបនិស្ស័យស្រឡាញ់ចូលចិត្តការងារឧស្សាហកម្ម សិប្បកម្ម។

គោលគំនិតនេះ ត្រូវបានអង្គការ UNESCO ចាត់ទុកជាកម្មវិធីអាទិភាពដែលហៅថា ការសិក្សានិងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីកសាងសមត្ថភាពមូលដ្ឋាន សមត្ថភាពបច្ចេកទេសនិងវិជ្ជាជីវៈ សមត្ថភាពដែលអាចផ្ទេរបាន ពីវិជ្ជាជីវៈ១ទៅ១ទៀត ចំពោះសិស្ស និស្សិត ដែលត្រូវរកការងារធ្វើ និងចង់រស់នៅសមរម្យ ។ តើយើងត្រូវធ្វើយ៉ាងដូចម្តេចដើម្បីឲ្យកម្មវិធី "**ការសិក្សា និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**" អាចផ្តល់ផលប្រយោជន៍ដល់ការអភិវឌ្ឍ អាចរកឃើញមធ្យោបាយថ្មីដើម្បីសម្រួលអន្តរកាល ពីសាលារៀនទៅការងារនិងអាចតម្រង់ទិសដៅកែប្រែស្ថានភាពសព្វថ្ងៃ។ដូចនេះការអំពាវនាវរកជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍អន្តរជាតិ ជាសំណូមពរចាំបាច់។

ប្រទេសទាំងអស់រួមទាំងកម្ពុជាផង បានគាំទ្រទស្សនៈនេះ និងបានកំណត់ជាត្រីវិស័យ ក្នុងដំណើរការអនុវត្តកម្មវិធី "**ការសិក្សា និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**" តាមស្ថានភាពជាក់ស្តែងរៀងៗខ្លួន។

អ្វីដែលបានលើកឡើងនេះ ក៏មានខ្លឹមសារប្រហាក់ប្រហែលគ្នានឹងគំនិតផ្តួចផ្តើម របស់លោកអគ្គលេខាធិការ អ.ស.ប. បានគីមូន (Ban Ki-moon) គឺ "ចូររួបរួមគ្នា ដើម្បីយកចិត្តទុកដាក់ដល់ការអប់រំ មុនអ្វីៗទាំងអស់" ព្រោះការអប់រំជាមធ្យោបាយ មានប្រសិទ្ធភាពបំផុតដើម្បីកាត់បន្ថយភាពក្រីក្រ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដើម្បីលើកកម្ពស់សុខភាព និង សុខុមាលភាព ដើម្បីពង្រឹងការលូតលាស់សេដ្ឋកិច្ច និងដើម្បីជំរុញលក្ខណៈជាពលរដ្ឋដែលមានការទទួលខុសត្រូវ ។ គំនិតនេះ គឺជាគំនាស់ឈានមុខរបស់ "ការអប់រំសម្រាប់ទាំងអស់គ្នា" ។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ** បានកំណត់ច្បាស់ថា " **ជោគជ័យនៃគ្រប់វិស័យរបស់ប្រទេសជាតិ វាអាស្រ័យនឹងការចូលរួមរបស់ប្រជាជនរាប់ទាំងវិស័យអប់រំផងដែរ** " ៕

**គណៈកម្មាធិការកណ្តាល ស.ប.ស.ខ.**

# សេចក្ដីសម្រេច

ស.ប.ស.ខ.
AMCEK

**សមាគមបុគ្គលិកសិក្សាខ្មែរ**

Association Mutualiste du Corps Enseignant Khmer/
Ligue Cambodgienne de l'Enseignement

លេខៈ ០៩/១៥ គ.ក

## សេចក្ដីសម្រេច
## ស្ដីពីការបែងចែកភារកិច្ចរបស់គណៈកម្មាធិការ ស.ប.ស.ខ. ថ្មី

~~~~~o~~~~~

**ព្រឹទ្ធសមាជិកនៃគណៈកម្មាធិការ ស.ប.ស.ខ. ថ្មី**

- យោងលក្ខន្តិកៈសមាគមបុគ្គលិកសិក្សាខ្មែរ
- យោងសេចក្ដីសម្រេចចិត្តរបស់មហាសន្និបាត ស.ប.ស.ខ. អាណត្តិទី១១
- ផ្អែកលើមតិឯកភាពជាឯកច្ឆន្ទរបស់អង្គប្រជុំគណៈកម្មាធិការ ស.ប.ស.ខ.ដំបូងចុះថ្ងៃទី១២ ខែកុម្ភៈឆ្នាំ២០១៥
- តាមការចាំបាច់

**សម្រេច**

**ប្រការ១**

កំណត់របៀបរបបការងារ និងបែងចែកភារកិច្ចជូនសមាជិកសមាជិកា គណៈកម្មាធិការ ស.ប.ស.ខ.ថ្មី ក្នុងគោលបំណងធានាប្រក្រតីភាព និងប្រសិទ្ធភាពនៃការដឹកនាំគ្រប់គ្រងដំណើរការរបស់សមាគមបុគ្គលិកសិក្សាខ្មែរ ។

**ប្រការ២**

តែងតាំងគណៈកម្មាធិការកណ្ដាល ដែលមានសមាសភាពដូចខាងក្រោម៖

១. ឯកឧត្តម **យស់ អ៊ែន** **ប្រធាន** ទទួលបន្ទុកត្រួតពិនិត្យលើការដឹកនាំគ្រប់គ្រងកិច្ចការទូទៅ របស់ ស.ប.ស.ខ.។

២. លោកជំទាវ **ទន់ សាអ៊ីម** **អនុប្រធាន** ជួយប្រធានលើគ្រប់កិច្ចការ និង ជំនួសប្រធាន ពេលអវត្តមានដោយមូលហេតុផ្សេងៗ។
~~~~~

៣. ឯកឧត្តម **អ៊ិន ថេរ អគ្គលេខាធិការ** ទទួលបន្ទុកការងាររដ្ឋបាល និង ទំនាក់ទំនងក្នុង-ក្រៅសមាគម។

៤. លោក **នៀ សុផន អគ្គលេខាធិការរង** ជួយអគ្គលេខាធិការលើគ្រប់កិច្ចការរបស់អគ្គលេខាធិការ។

៥. លោកស្រី **គុយ ផល្លា អគ្គហេរញ្ញិក** ទទួលបន្ទុកការងារគណនេយ្យ ហិរញ្ញកិច្ចនិងបេឡា។

៦. លោក **ស៊ិន ស៊ីម អគ្គហេរញ្ញិករង** ជួយអគ្គហេរញ្ញិកលើគ្រប់កិច្ចការរបស់អគ្គហេរញ្ញិក។

៧. លោក **រ័ត្ន ហូត បណ្ណារក្ស** ទទួលបន្ទុកដំណើរការបណ្ណាល័យ និងរៀបចំទស្សនាវដ្ដីគ្រូបង្រៀន។

៨. លោក **ជ័យ សយ្យនា បណ្ណារក្ស** ទទួលបន្ទុកដំណើរការបណ្ណាល័យ និងការរៀបចំទស្សនាវដ្ដីគ្រូបង្រៀន ។

៩. ឯកឧត្តម **ថោង ប៉ូវ៉ាន់ សួនការ**ទទួលអនុវត្តគ្រប់កិច្ចការដែលប្រធាន ស.ប.ស.ខ. ប្រគល់ឲ្យ ។

១០. លោកស្រី **ប្រាក់ សុលីដា សួនការ** ទទួលអនុវត្តកិច្ចការដែលប្រធាន ស.ប.ស.ខ. ប្រគល់ឲ្យ។

១១. លោក **ជន ឈាងលី សួនការ** ទទួលអនុវត្តកិច្ចការដែលប្រធាន ស.ប.ស.ខ. ប្រគល់ឲ្យ។

១២. លោក **ព្រុំ សាមិត សួនការ** ទទួលអនុវត្តគ្រប់កិច្ចការដែលប្រធានស.ប.ស.ខ. ប្រគល់ឲ្យ។

**ប្រការ៣**

តែងតាំង**គណៈកម្មាធិការត្រួតពិនិត្យ** ដែលមានសមាសភាពដូចខាងក្រោម៖

១. លោក **សួង សារុណា ប្រធាន** ទទួលបន្ទុកត្រួតពិនិត្យការកាន់កាប់ហិរញ្ញវត្ថុរបស់ ស.ប.ស.ខ. និងរាយការណ៍ជាលាយលក្ខណ៍អក្សរ ១ឆ្នាំម្តង ជូនគណៈកម្មាធិការកណ្តាល និង ៥ឆ្នាំ ជូនមហាសន្និបាត ។

២. លោក **ស៊ុង ចាន់ថន សមាជិក** ជួយគ្រប់ភារកិច្ចរបស់ប្រធាន ។

៣. លោកស្រី អ៊ឹម ប៊ុណ្ណារី **សមាជិកា** ជួយគ្រប់ភារកិច្ចរបស់ប្រធាន ។

**ប្រការ៤**

**គណៈកម្មាធិការកណ្តាល គណៈកម្មាធិការរាជធានី-ខេត្ត និងអង្គភាពជុំវិញក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសាមីជនដូចប្រការ២**-៣ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

**ភ្នំពេញ, ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥**

**ក្នុងនាមគណៈកម្មាធិការកណ្តាល ស.ប.ស.ខ.**

**ព្រឹទ្ធសមាជិក** [signature]

**ស៊ុង ចាន់ថន**

**កន្លែងទទួល៖**

- ក្រសួងអប់រំ យុវជននិងកីឡា
  (ដើម្បីជូនជ្រាបជាពត៌មាន)
- គ្រប់គណៈកម្មាធិការ និងអង្គភាព
  (ដើម្បីសហការ)
- សាមីជន ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ

# ច្បាប់ស្តីពីការអប់រំ

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ៥៥.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧
ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ពាល.០៧១២.៦២៤

**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
**ហត្ថលេខា**
**គុល ផង**

លេខ: ៩៧១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៧
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**ឃុន ជិនកេន**

# ឧបសម្ព័ន្ធ

**ករណីយកិច្ច** : សំដៅដល់កិច្ចការដែលត្រូវតែធ្វើតាមវិធានច្បាប់ដែលបានចែង ។

**ក្រសួងទទួលបន្ទុកវិស័យអប់រំ**: សំដៅដល់ស្ថាប័នសាធារណៈណាមួយដែលទទួលខុសត្រូវលើវិស័យអប់រំ ទោះជាស្ថាប័ននោះ ទទួលបន្ទុកការងារផ្សេងទៀតក៏ដោយ ។ ការប្រើពាក្យបែបនេះ គឺដើម្បីឱ្យចំស្ថាប័នមួយ ដែលទទួលបន្ទុកកិច្ចការអប់រំដែលជាធម្មតាមានការផ្លាស់ប្តូរឈ្មោះតាមអាណត្តិរបស់រាជរដ្ឋាភិបាល ។

**កាតព្វកិច្ច**: សំដៅដល់ចំណងតាមផ្លូវច្បាប់ ដែលបង្ខំឱ្យត្រូវតែធ្វើ ។

**ការអប់រំក្នុងប្រព័ន្ធ** : សំដៅដល់ដំណើរការសិក្សាដែលមានលក្ខណៈជាប្រព័ន្ធ និង ហ្មត់ចត់មានរចនាសម្ព័ន្ធរៀបរយ និងតាមលំដាប់ថ្នាក់ ។ ការអប់រំក្នុងប្រព័ន្ធផ្តល់ឱ្យដោយគ្រឹះស្ថានសិក្សា ដែលមានអាជ្ញាបណ្ណអប់រំត្រឹមត្រូវ ឬ ដែលមានការទទួលស្គាល់គុណភាពអប់រំស្របតាមលក្ខខណ្ឌផ្នែកច្បាប់ និងនីតិវិធីដែលមានចែងក្នុងច្បាប់នេះ ។

**ការអប់រំក្រៅប្រព័ន្ធ**: សំដៅដល់សកម្មភាពអប់រំ ដែលមានការរៀបចំមានលក្ខណៈជាប្រព័ន្ធ ដែលធ្វើឡើងនៅក្រៅក្របខ័ណ្ឌនៃកម្មវិធីអប់រំក្នុងប្រព័ន្ធ ដើម្បីផ្តល់ការសិក្សាមួយចំនួនដែលបានជ្រើសរើស ។ ការអប់រំក្រៅប្រព័ន្ធគ្របដណ្តប់លើកម្មវិធីអប់រំជាច្រើន ដូចជាអក្ខរកម្ម បំណិនជីវិត បំណិនការងារ ការអប់រំមូលដ្ឋាន សម្រាប់អ្នកសិក្សាដែលមិនចូលសិក្សានៅគ្រឹះស្ថានសិក្សាក្នុងប្រព័ន្ធ ដែលមានលក្ខណៈជាការសិក្សាបន្ត និងការសិក្សាកម្រិតសមមូលសម្រាប់ការបញ្ចូលទៅក្នុងកម្មវិធីអប់រំក្នុងប្រព័ន្ធ ឬ ជាការអប់រំអស់មួយជីវិត ។ អ្នកសិក្សាក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធមានសិទ្ធិសុំ និងទទួលបាននូវការធ្វើតេស វាយតម្លៃកម្រិតសមមូលចំពោះការអប់រំរបស់ខ្លួនពីអាជ្ញាធរអប់រំមានសមត្ថកិច្ចដូចមានចែងក្នុងច្បាប់នេះ ។

**ការអប់រំមិនផ្លូវការ**: សំដៅដល់ដំណើរការស្វ័យសិក្សា ឬ ការសិក្សាដោយខ្លួនឯង និងជាដំណើរការសិក្សាអស់មួយជីវិត តាមការចាប់អារម្មណ៍ សក្តានុពលការត្រៀមខ្លួនជាស្រេច និងឱកាសដែលមាន ហើយដែលអ្នកសិក្សាទទួល និងបង្កើនផ្តុំចំណេះដឹង ជំនាញ ឥរិយា-

បថ និងគំនិតបានមកពីបទពិសោធប្រចាំថ្ងៃពីការងារ ការសំដែង និងពីជីវិតផ្ទាល់ និងជាការសិក្សាតាមរយៈមនុស្ស សង្គម មជ្ឈដ្ឋានជុំវិញប្រព័ន្ធសារព័ត៌មាន ព្រមទាំងប្រភពចំណេះដឹង ឬ ប្រភពព័ត៌មានផ្សេងទៀតនៅពេលណា និង នៅទីកន្លែងណាផ្សេងទៀតក៏ដោយក្រៅពីកម្មវិធីអប់រំក្នុងប្រព័ន្ធ និងកម្មវិធីអប់រំក្រៅប្រព័ន្ធ ។ អ្នកសិក្សាមានសិទ្ធិសុំ និងទទួលការធ្វើតេស្តវាយតម្លៃកម្រិតសមមូល ចំពោះការអប់រំរបស់ខ្លួនពីអាជ្ញាធរអប់រំមានសមត្ថកិច្ចដូចមានចែងក្នុងច្បាប់នេះ ។

**ការអប់រំសម្រាប់ទាំងអស់គ្នា** : សំដៅដល់ចលនារបស់ពិភពលោក ដើម្បីឱ្យកុមារ យុវជន និងជនពេញវ័យគ្រប់រូប មានសិទ្ធិទទួលផលប្រយោជន៍ពីការអប់រំបានយ៉ាងពេញលេញ និងប្រកបដោយគុណភាពខ្ពស់ ។

**ការអប់រំមានគុណភាព** : សំដៅដល់ការអប់រំមួយ ដែលបំពេញបានសេចក្តីត្រូវការនៃការសិក្សាជាមូលដ្ឋាន និងបន្តអស់មួយជីវិតរបស់អ្នកសិក្សា ។

**កម្មវិធីសិក្សា** : សំដៅដល់សំណុំមុខវិជ្ជា ដែលត្រូវបានរៀបចំឱ្យអ្នកសិក្សា ទទួលបាននូវចំណេះដឹង ចំណេះធ្វើ សីលធម៌ និងសមត្ថភាពបន្តការសិក្សាពេញមួយជីវិតស្របតាមបទ-បញ្ញត្តិនៃច្បាប់នេះ ។

**កម្មវិធីសិក្សាគោល**: សំដៅដល់កម្មវិធីសិក្សាដែលកំណត់ដោយអាជ្ញាធរអប់រំមានសមត្ថកិច្ចសម្រាប់ឱ្យគ្រឹះស្ថានសិក្សា ត្រូវតែអនុវត្តតាមកម្មវិធីនេះជាដាច់ខាត ។

**ការអប់រំពិសេស** : សំដៅដល់ការអប់រំបណ្តុះបណ្តាល ដើម្បីផ្តល់ដល់ជនដែលមានតម្រូវការពិសេសដូចជាជនពិការ និងអ្នកសិក្សាពូកែមានបញ្ញាខ្ពស់ ។

**ការបន្លំបោកប្រាស់ក្នុងការអប់រំ**: សំដៅដល់ការសូកប៉ាន់ ការទទួលសំណូក ការក្លែងបន្លំគ្រប់រូបភាព ក្នុងដំណើរការអប់រំ មានជាអាទិ៍ ការទិញលក់សញ្ញាបត្រ ឬវិញ្ញាបនបត្រ វិញ្ញាសាប្រឡងថ្នាក់ជាតិ និងវិញ្ញាសាតេស្តវាស់ស្ទង់ការអប់រំកម្រិតសមមូល ឬ ការប្រឡងជំនួស ។




## ពាក្យគន្លឹះក្នុងការងារផែនការអប់រំ
## ( តចប់ )

**៤.សកម្មភាពគោលនយោបាយ** ( Policy action )

សកម្មភាពគោលនយោបាយសំដៅលើការរៀបចំកសាងក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្ដីណែនាំ និងផែនការសកម្មភាព។ សកម្មភាពគោលនយោបាយ គឺជាការប្រែក្លាយពីយុទ្ធសាស្ត្រឲ្យទៅជាសកម្មភាព ដែលនឹងត្រូវយកទៅអនុវត្តជាលក្ខណៈទូលំទូលាយ ឬជាក្រុមៗ។ ពីព្រោះ យុទ្ធសាស្ត្រ ជាឃ្លាប្រយោគដែលគេមិនអាចកំណត់ច្បាស់ថាត្រូវយកមកអនុវត្តបែបណានោះទេ លុះត្រាតែរៀបចំទៅជាសកម្មភាពគោលនយោបាយសិន។

ឧទាហរណ៍ : យុទ្ធសាស្ត្រមួយលើកឡើងថា " ធានាការចូលរៀនរបស់កុមារអាយុ ៦ឆ្នាំនៅបឋមសិក្សា "។ ដូចនេះសកម្មភាពគោលនយោបាយមួយ អាចត្រូវបានលើកឡើងថា " ចេញក្រឹត្យ និងសេចក្ដីណែនាំសម្រាប់កុមារអាយុ ៦ឆ្នាំចូលរៀននៅបឋមសិក្សា ដោយផ្សារភ្ជាប់ទៅនឹងការពង្រីកការអប់រំកុមារតូចអាយុ ៥ឆ្នាំ"។( ESP,2006 )។

**៥.សកម្មភាពចម្បង** ( Main activities )

សកម្មភាពចម្បងគឺជា បណ្ដុំសកម្មភាពដែលត្រូវអនុវត្ត ដើម្បីរួមចំណែកសម្រេចគោលបំណង។ វាជាការប្រែក្លាយចេញពីយុទ្ធសាស្ត្រ ទៅជាកម្មវិធី ឬគម្រោង ( ជាទូទៅ គេអាចស្គាល់វាតាមរយៈ ឈ្មោះកម្មវិធី ឬឈ្មោះគម្រោង )។ នៅក្នុងសកម្មភាពចម្បង មានលើកឡើងនូវសកម្មភាពលំអិតដែលត្រូវយកមកអនុវត្ត។សកម្មភាព ឬសកម្មភាពលំអិតនោះ អាចឆ្លុះបញ្ចាំងឲ្យឃើញពីចំណាយ( ធនធានមនុស្ស សម្ភារៈនិងថវិកា )ទៅតាមប្រភេទនីមួយៗរបស់សកម្មភាព។

**៦.គោលដៅ** ( Goals )

គោលដៅគឺជាសេចក្ដីប្រាថ្នាកម្រិតខ្ពស់លើផ្នែកសង្គម-សេដ្ឋកិច្ចរបស់កម្មវិធីមួយ ដែលលើកឡើងក្នុងន័យទូលំទូលាយ។ ឧទាហរណ៍ ការផ្ដល់នូវការចូលរៀនដោយឥតគិតថ្លៃនៅបឋមសិក្សាសម្រាប់កុមារទាំងអស់ជាមួយគ្នានឹងការអប់រំប្រកបដោយគុណភាព។ល។ គោលដៅ ជាខ្លឹមសារដែលបរិយាយក្នុងន័យទូលំទូលាយ បង្ហាញពីការសម្រេចបានជាទូទៅក្នុងរយៈពេលដ៏យូរអង្វែង ( ច្រើនជាង ១០ឆ្នាំ )។ គោលដៅត្រូវបានគេរំលេចឡើងនៅក្នុងផែនការយុទ្ធសាស្ត្រ។

**៧.វត្ថុបំណងរបស់ផែនការ** ( Objectives )

វត្ថុបំណង (ឬវត្ថុបំណងជាយុទ្ធសាស្ត្រ) គឺជាលទ្ធផលដែលរំពឹងទុក តាមរយៈការអនុវត្តផែនការរយៈពេលមធ្យម (ជាការអនុវត្តយុទ្ធសាស្ត្រ)។ លទ្ធផលដែលសម្រេចបាននេះ ចូលរួមចំណែកក្នុងការសម្រេចបានទិសដៅគោលនយោបាយរយៈពេលវែង( **long-term policy goals** )។

**៨.ចំណុចដៅ** ( Target )

ចំណុចដៅគឺជា ការកំណត់ពីលទ្ធផលជាក់លាក់ និងអាចវាស់វែងបាន ក្នុងការសម្រេចបានពីការអនុវត្តកម្មវិធីនានា ដែលរួមចំណែកសម្រេចវត្ថុបំណងនានា (គោលដៅ និងវត្ថុបំណងរបស់ផែនការ)។

**៩.កម្មវិធីអប់រំ** ( Educational programs )

កម្មវិធីអប់រំគឺជា ក្របខ័ណ្ឌនៃសកម្មភាពដែលទាក់ទងគ្នា ដែលរៀបចំឡើងដើម្បីបានវត្ថុបំណងទូទៅ។ នៅក្នុងកម្មវិធីអប់រំរួមមាន បណ្តុំនៃសកម្មភាព ដែលបង្កើតឡើងក្នុងគោលបំណងសម្រេចវត្ថុបំណងជាក់លាក់ (កម្រិតទាប)។

ដកស្រង់ពីឯកសារនាយកដ្ឋានផែនការ (លោកស្រី **គុយ ផល្លា**)

## ច្បាប់ល្បើកថ្មី

កុំថ្នមកម្លាំង
រៀនអ្វីឲ្យឆ្អិន

កាប់ដីកចូកចាំង
កុំឲ្យខ្លោចឆៅ
ក្រក្រៅសណ្ដាប់។

កុំថារងាក្ដៅ
កុំដេកតែខ្លៅ

បើល្ងង់ឲ្យចេះ
ឥន្ទ្រិយធ្វេងស្ដាំ

រករៀនតម្រិះ
កុំចាំគេប្រាប់
រៀនមើលឲ្យស្ពៃង។

រិះរកតម្រាប់
រៀនស្ដីរៀនស្ដាប់

កើតមកជាមនុស្ស
បើក្រឲ្យមាន

ទាំងស្រីទាំងប្រុស
វិញ្ញាណចេះក្រែង
កុំដេកតែក្រ។

មិនដែលចេះឯង
គិតគ្រប់កន្លែង

**គិរម្យ ទុំយ**

# ប្រវត្តិនៃការអប់រំក្នុងពិភពលោក(ត)

## ឃ.ស្វ័យពិនិត្យ ការសន្ទនា និងវិធីបែបសូក្រាត

គោលបំណងអប់រំបែបសូក្រាត គឺត្រូវជួយបុគ្គលឲ្យកំណត់ខ្លួនគេ តាមស្វ័យពិនិត្យ។ តាមរបៀបនេះបុគ្គលម្នាក់អាចស្វែងរកការពិត ដែលមានជាសកលក្នុងគ្រប់មនុស្សទាំងអស់។ ក្នុងនាមជាគ្រូម្នាក់ សូក្រាត បានសួរសំណួរនាំមុខដែលភ្ញោចសិស្ស ដើម្បីស៊ើបអង្កេតនូវការយកចិត្តទុកដាក់របស់មនុស្សតាំងពីយូរ (perennial human concerns) អំពីអត្ថន័យនៃជីវិត ការពិត និងយុត្តិធម៌។ បន្ទាប់មកសិស្សមានការពិភាក្សាយ៉ាងសកម្ម តែឲ្យមានភាពលំបាក ឬការសន្ទនា ដែលក្នុងនោះសិស្សបញ្ជាក់អះអាង ទិតៀន និងបង្កើតឡើងវិញនូវបញ្ញត្តិមូលដ្ឋានរបស់ពួកគេ។ ចំពោះសូក្រាត ការសន្ទនា មិនមែនមានន័យថា គ្រាន់តែចែករំលែកគំនិតនោះទេ។ វាមានន័យថា ការឆ្លុះបញ្ចាំង និងការទិតៀនពួកគេឲ្យរកឃើញសច្ចភាពជាមូលដ្ឋាន(the underlying truth)។ គោលវិធីនេះ នៅតែត្រូវបានគេទទួលស្គាល់ថាគឺជាវិធីសូក្រាត។ ក្នុងនាមជាគ្រូម្នាក់ អ្នកអាចប្រើវិធីសូក្រាត តាមការសួរសំណួរដល់សិស្ស ដែលបានរៀបចំជាស្រេចដើម្បីចម្រាញ់យកការគិតល្អិតល្អន់របស់ពួកគេ ទៅលើបញ្ហាថ្មីៗ ឬជាប្រវត្តិសាស្ត្ររបស់ពួកគេ ឬអំពីស្នាដៃអក្សរសាស្ត្រដែលត្រូវបានដាក់ឲ្យសិស្សអាន។

ដោយប្រៀបបាននឹងទីផ្សារអាថែន ដែលបានកើតឡើងជាញឹកញាប់នោះ សូក្រាត បានទាក់ទាញក្រុមមនុស្សក្មេងៗដែលបានចូលរួមជាមួយគាត់ក្នុងការពិនិត្យដោយល្អិតល្អន់នៃប្រភពបញ្ហាទាំងអស់ដូចជាសាសនា នយោបាយ សីលធម៌ និងសោភ័ណវិទ្យា(esthetics)។ ក្នុងនាមជាអ្នករិះគន់ទៅលើសង្គមវិញ សូក្រាត បានបង្កើតសត្រូវដ៏មានឥទ្ធិពល។ ដូច្នេះហើយ ក្នុងពេលឥឡូវនេះ មនុស្សមួយចំនួន ដោយរាប់បញ្ចូលទាំងមនុស្សដែលមានឋានៈខ្ពង់ខ្ពស់ផងដែរ បានភ័យខ្លាចថា ការគិតដ៏ល្អិតល្អន់ អាចប្រឆាំងនឹងការងាររបស់ពួកគេ ហើយនាំទៅដល់ចលាចល។ នៅក្នុងឆ្នាំ ៣៩៩ មុនគ.ស ក្រោយពេលបានវិនិច្ឆ័យការចោទប្រកាន់ពីការខ្វះសេចក្តីគោរព(impiety) ដល់ព្រះជាម្ចាស់ និងអំពើពុករលួយទៅលើយុវជនអាថែន សូក្រាតត្រូវបានគេកាត់ទោសប្រហារជីវិត(Socrates was condemned to death) គឺជាការកាត់ទោសមួយដែលគាត់មិនបានប្រកែកតវ៉ា។

## ៥.៣.ប្លាតុង សច្ចភាព និងតម្លៃអនន្ត

### ក.ភាពពិតជាសកល និងគំនិតអនន្ត

ប្លាតុងជាកូនសិស្សរបស់សូក្រាត(៤២៧-៣៤៦ មុនគ.ស)ដើរតាមផ្លូវជាអ្នកអប់រំរបស់គាត់។ ប្លាតុង បានបង្កើតបណ្ឌិត្យសភា ដែលជាសាលារៀនខាងទស្សនវិជ្ជា នៅឆ្នាំ ៣៨៧ មុនគ.ស។គាត់បាននិពន្ធ Protagoras ដែលជាសេចក្តីថ្លែងស្តីអំពីគុណធម៌ និងសាធារណរដ្ឋ និងច្បាប់ អភិប្រាយអំពីនយោបាយ ច្បាប់ និងការអប់រំ[២០]។ដោយជំទាស់នឹងសច្ចភាពមិនមានលំនឹងរបស់ពួកសូហ្វីស ប្លាតុងបានអះអាង ថាការពិត កើតមានពីពិភពមិនប្រែប្រួលនៃគំនិតឥត-ខ្ចោះ គឺបញ្ញត្តិសកល ដូចជា សច្ចភាព កុសល យុត្តិធម៌ និងសោភ័ណភាព។ករណីបុគ្គលនៃបញ្ញត្តិទាំងនេះ ដូចដែលវាបានបង្ហាញខ្លួន ចំពោះវិញ្ញាណរបស់យើង គឺគ្មានអ្វីក្រៅពីការបង្ហាញអសុក្រឹតនៃបញ្ញត្តិសកល និងអនន្ត ដែលមាននៅក្នុងគំនិតដាច់ខាតគឺទម្រង់នៃកុសល។

(20) Devin Stuffer , Platon's Introduction to the Question of Justice (Albany : State University of New York Press, 2000).

**ខ.ការរំឭកពីរឿងដើម**

ទ្រឹស្ដីប្លាតុងនៃផ្នែកចំណេះដឹង គឺផ្អែកលើការរំឭកពីរឿងដើម( reminiscence )គឺជាលំនាំដែលបុគ្គលចងចាំគំនិតដែលមាន តែមិនទាន់បង្ហាញឲ្យឃើញក្នុងចិត្ត។ ការរំឭករឿងដើម អះអាងថា ព្រលឹងមនុស្ស មុនពេលចាប់កំណើតបានរស់នៅក្នុងពិភពខាងស្មារតី គឺជាប្រភពនៃសច្ចភាព និងចំណេះដឹង។នៅពេលកើតគំនិតពីកំណើតទាំងនេះត្រូវបានទប់នៅក្នុងគំនិតអនុញ្ញាណ ។ ចំពោះប្លាតុង ការសិក្សាមានន័យថា គេអាចរកឃើញឡើងវិញឬចងចាំគំនិតឥតខ្ចោះទាំង នេះ[២១]។

**គ.សកលនិយម ទល់នឹងសច្ចភាពមិនមានលំនឹង**

មិនដូចសភាពផ្លាស់ប្ដូរបានរបស់សច្ចភាពមិនមានលំនឹង សកលនិយម អះអាងថា ស្មាមជិតខាងវិញ្ញាណធ្វើឲ្យខុសពីភាពពិត ចំណេះដឹងពិត គឺខាងបញ្ញា មិនផ្លាស់ប្ដូរ និងអនន្ត មិនមែនឥន្ទ្រីយារម្មណ៍ទេ។ មិនមានគំនិតណាមួយល្អឥតខ្ចោះសម្រាប់មនុស្សទាំងអស់ ដោយមិនគិតពីពេល ឬកន្លែងដែលគេរស់នៅ។ ពីព្រោះការពិត នៅតែជាការពិត ការអប់រំ គួរតែមានលក្ខណៈសកល និងមិនប្រែប្រួលផងដែរ។

**ឃ.គំនិតពីកំណើត**

ជំនឿដែលថា គំនិតពីកំណើត មានតែមិនទាន់បង្ហាញឲ្យឃើញនៅក្នុងចិត្ត មានឥទ្ធិពលខាងអំណាច ទៅលើការអប់រំលោកខាងលិចពីសម័យដើម។ ការអប់រំនៅឥណ្ឌា ក៏បានឆ្លុះបញ្ចាំងជំនឿក្នុងគំនិតពីកំណើត។ការអប់រំផ្នែកវេទបានលើកទឹកចិត្តឲ្យមានការតាំងភាវនា ដើម្បីរកឲ្យឃើញចំណេះដឹងពីកំណើត ។ នៅលោកខាងលិច ទ្រឹស្ដីគំនិតពីកំណើតត្រូវបានប្រឆាំងដោយអ្នកធ្វើកំណែទម្រង់ផ្នែកអប់រំនាពេលក្រោយមក ដូចជា Locke, Pestalozzi, Dewey និងអ្នកផ្សេងទៀត ដែលគំនិតរបស់គេត្រូវបានសិក្សានៅពេលក្រោយ។ វិវាទផ្នែកអប់រំនាពេលក្រោយជាច្រើន ដែលសូម្បីតែប្រយោជន៍នាពេលបច្ចុប្បន្នក្នុងអ្នកស្ថាបនានិយម អាចត្រូវបានគេមើលឃើញថា ជាការអះអាងតបចំពោះទ្រឹស្ដីនៃគំនិតរបស់ប្លាតុងដែរ។

**ង.សាធារណរដ្ឋ**

វាជាសង្គមប្រកបដោយឧត្ដមគតិរបស់ប្លាតុង។ នៅក្នុងសាធារណរដ្ឋរបស់ប្លាតុង គាត់បានរៀបចំគម្រោងផែនការសម្រាប់សង្គមល្អឥតខ្ចោះមួយ ដែលគ្រប់គ្រងដោយអធិរាជទស្សនៈវិជ្ជា ដែលជាវរជនខាងបញ្ញា។ ទោះបីជារដ្ឋដែលជាឧត្ដមគតិរបស់ប្លាតុង មិនដែលត្រូវបានគេអនុវត្តក៏ដោយ ក៏គំនិតរបស់គាត់មានប្រយោជន៍ក្នុងការពិពណ៌នាកំណែប្រែថ្មីដែលជាឧត្ដមគតិនៃប្រភេទការអប់រំជីពិតប្រាកដមួយ[២២]។ សាធារណរដ្ឋ បានបែងចែកវណ្ណៈ ៣គឺ :

១-អធិរាជទស្សនវិជ្ជាៈ អ្នកដឹកនាំដែលជាបញ្ញវន្ត។

២-អ្នកជំនួយ : អ្នកការពារដែលជាកងទ័ព។

៣-កម្មករ : អ្នកផលិតទំនិញ ផ្ដល់សេវាកម្ម។ សមត្ថភាពប្រកបដោយភាពឈ្លាសវៃរបស់មនុស្សម្នាក់ នឹងកំណត់ កិច្ចការខាងវណ្ណៈរបស់ខ្លួន។

ភាពស្រដៀងគ្នាបានកើតមានឡើង រវាងគំនិតខុង ជឺ ឥណ្ឌាបុរាណ និងប្លាតុង។ តាមគំនិតទាំង ៣ នេះ សង្គមគួរតែត្រូវបានរៀបចំរចនាសម្ព័ន្ធ ទៅតាមឋានានុក្រម ជាមួយមនុស្សដែលមានប្រាជ្ញាបំផុតស្ថិតនៅក្នុងតំណែងកម្រិតខ្ពស់ បំផុតនៃអាជ្ញាធរ។ ផ្ទុយទៅវិញ សង្គមតាមបែបឋានានុក្រមបែបនេះ ពួកសូហ្វីស អះអាងថា អ្នកណាម្នាក់ក៏អាចឡើងទៅដល់កម្រិតកំពូលបានដែរ ប្រសិនបើគេទទួលបានបច្ចេកទេស ដែលផ្ដល់អំណាចដល់ពួកគេបាន។

( នៅមានត )

អនុបណ្ឌិត **សួរ សុធី**

(21)Gerald L. Gutek, Historical and Philosophical Foundations of Education : A Biographical Introduction (Columbus, Ohio : Merril/Prentice Hall, 2005), pp.37-40.

(22)Platon,Republic(London :Folio Society,2003, also see Selected Dialogues of Plato:The Benjamin Jowett Translation(New York:Modern Library, 2001),



# ចិត្តវិទ្យាអប់រំ

## អត្តចរិត

### ១-សញ្ញាណទូទៅនៃអត្តចរិត

អត្តចរិត ជាលក្ខណៈចិត្តរបស់បុគ្គល ដែលសម្ដែងប្រាប់នូវឥរិយាបថរបស់បុគ្គលនោះ ចំពោះពិភពបរានុម័ត ។ គេអាចនិយាយបានថា អត្តចរិតរបស់មនុស្សម្នាក់ៗ គឺជាបុគ្គលិកលក្ខណៈរបស់បុគ្គល ខាងផ្នែកគុណធម៌ សីលធម៌ ទម្លាប់និង ឥរិយាបថ ដែលទាំងអស់នេះសម្ដែងឡើងដោយអំពើ និងអាកប្បកិរិយារបស់បុគ្គលនោះ ក្នុងការងារ ក្នុងការសិក្សា ក្នុងជីវភាពរស់នៅប្រចាំថ្ងៃក្នុងសង្គម។

ឧ. សិស្ស "ក" ឧស្សាហ៍រៀនសូត្រ រៀនមេរៀន ធ្វើកិច្ចការផ្ទិតផ្ទង់ មានរបៀបរៀបរយ ។ល។ សិស្ស "ខ" ជាមនុស្ស រម្យទម ចុះសម្រុងនឹងសង្គម ត្រូវបានមិត្តភ័ក្ដិរាប់អានដោយសុទ្ធចិត្ត។ សិស្ស "គ" ជាអត្តទត្ថបុគ្គល គិតតែប្រយោជន៍ផ្ទាល់ខ្លួន គ្មានគិតប្រយោជន៍អ្នកដទៃ ឬ ប្រយោជន៍សង្គម។

លក្ខណៈឧស្សាហ៍រៀនសូត្រ ភាពរម្យទម ភាពចុះសម្រុង និងអត្តទត្ថបុគ្គល ទាំងនេះជាអត្តចរិតរបស់បុគ្គលម្នាក់ៗឬហៅម៉្យាង ទៀតបានថា កិរិយាមារយាទ។ ដូចនេះមនុស្សម្នាក់ៗមានអត្តចរិតដោយឡែកៗពីគ្នា។ អត្តចរិតកើតមានដោយ ផ្ទាល់នៅក្នុងខ្លួនមនុស្សម្នាក់ៗ ហើយជះឥទ្ធិពលដោយផ្ទាល់តាមរយៈអំពើរបស់មនុស្សនោះ។

### ២-លក្ខណៈអត្តចរិត

ជាទូទៅ អត្តចរិតមានលក្ខណៈពីរផ្សេងគ្នា គឺជាគុណសម្បត្តិ និងគុណវិបត្តិ។ តាមធម្មតាអត្តចរិត ត្រូវបានគេកំណត់ទៅតាមសីលធម៌ដូចជា អត្តចរិតល្អ គឺជាគុណសម្បត្តិ។

ឧ.ឧស្សាហ៍រៀនសូត្រ ចុះសម្រុង គឺជាគុណសម្បត្តិ... ហើយអត្តចរិតអាក្រក់ គឺជាគុណវិបត្តិរបស់មនុស្សដូចជាអត្តទត្ថបុគ្គល ភាពខ្ជិល ភាពខ្វះស្មារតីទទួលខុសត្រូវ អំពើកោងកាច ។ល។ ភាពថ្លៃថ្នូរ ភាពចេះគួរសម គុណធម៌ សេចក្ដីអង់អាចក្លាហាន ភាពស្និទ្ធស្នាល ភាពទទួលខុសត្រូវលើការងារ ស្នេហាមាតុភូមិ ភាពអំណត់ក្នុងការងារ...ទាំងអស់នេះជាគុណសម្បត្តិរបស់មនុស្ស។ ការប្រព្រឹត្តអំពើទុច្ចរិត ភាពខ្ជិលច្រអូស ភាពក្រអឺតក្រទម ភាពវាយឫកពា ភាពចុះញ៉ម ភាពអសីលធម៌ ភាពមិនម្ចាស់ការទទួលខុសត្រូវលើការងារ ភាពគ្មានការចុះសម្រុង និងគ្មានទំនាក់ទំនងល្អនៅក្នុងសហគមន៍... ទាំងអស់នេះ ជាគុណវិបត្តិរបស់មនុស្ស។ ជាទូទៅ មនុស្សគ្រប់រូបតែងតែមានគុណសម្បត្តិផង និង គុណវិបត្តិផង។ក្នុងជីវិតរស់នៅ អត្តចរិតរបស់បុគ្គល អាចពង្រឹងបានដោយខ្លួនឯង តែក៏អាចផ្លាស់ប្ដូរដែរកាលណាលក្ខខណ្ឌសង្គមផ្លាស់ប្ដូរ។ ដូចនេះគេអាចផ្លាស់ប្ដូរអត្តចរិតមនុស្សបានតាមរយៈការអប់រំ។

១. សិស្សម្នាក់ទៅសាលារៀន នៅសាលារៀនសិស្សនេះនាំយកទៅជាមួយនូវទម្លាប់អាក្រក់មួយ គឺទម្លាប់លួច។ ទម្លាប់លួចនេះ សិស្សទទួលបានមកពីគ្រួសាររបស់គេ។ ប៉ុន្តែនៅសាលារៀនសិស្សបានទទួលឥទ្ធិពលអប់រំពីគ្រូ។ បន្តិចម្តងៗសិស្សនោះក៏ភ្លេចនូវទម្លាប់លួចនេះ ហើយក៏ក្លាយទៅជាអ្នកទៀងត្រង់ដូចគេឯង។

## ៣-ធម្មជាតិនៃអត្តចរិត

ដើម្បីធ្វើការសិក្សាស្រាវជ្រាវពីអត្តចរិតរបស់មនុស្សម្នាក់ៗ គេគប្បីសិក្សាស្វែងយល់ពីចរិតគ្រួសារ ចរិតមជ្ឈដ្ឋានរស់នៅជុំវិញរបស់បុគ្គលនោះ និងចរិតសង្គមជាមុនសិន។

រួមសេចក្តីមក អត្តចរិតគួបផ្សំដោយឥរិយាបថ ដែលត្រូវបានបែងចែកជាបីក្រុមៈ

-ឥរិយាបថចំពោះការងារ

-ឥរិយាបថចំពោះសង្គម និងបរិស្ថានជុំវិញ

-ឥរិយាបថចំពោះខ្លួនឯង។

គេនិយាយថា ក្នុងអត្តចរិត ទំនោរជាធាតុដឹកនាំ ឬទំនោរមាននាទីដឹកនាំ ជាអត្តចរិតរបស់មនុស្ស។

## ៤-ចំណុចសំខាន់ៗនៃអត្តចរិត

អត្តចរិតរបស់មនុស្ស គឺជាលក្ខណៈផ្លូវចិត្តរបស់មនុស្ស ដែលសម្តែងប្រាប់នូវឥរិយាបថ ឬ ឫកពាររបស់បុគ្គលចំពោះពិភពបរានុម័ត។ គេអាចធ្វើចំណាត់ថ្នាក់ ដោយធៀបទៅនឹងការងារសង្គម និងបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន។

### ៤.១-ការសម្តែងចេញនូវឥរិយាបថចំពោះការងារ

ឥរិយាបថចំពោះការងារ គឺជាការស្រឡាញ់ការងារ ការយកចិត្តទុកដាក់ និងដក់ចិត្តធ្វើការងារដោយទទួលខុសត្រូវ ព្រមទាំងការចេះដកស្រង់នូវបទពិសោធន៍ការងារ ដើម្បីពង្រីកគុណភាពផលិតកម្មរបស់ខ្លួន។ ដូច្នេះអ្នកដែលស្រឡាញ់ការងារ តែងតែធ្វើការប្រកបដោយស្មារតីទទួលខុសត្រូវ ចេះរៀបចំផែនការតាមបុរេវិនិច្ឆ័យ និងជានិច្ចកាលធ្វើស្វ័យសុក្រឹតការ សំដៅលើកកម្ពស់គុណភាពការងាររបស់ខ្លួន។

### ៤.២-ការសម្តែងចេញឥរិយាបថចំពោះសង្គម និងបរិស្ថានជុំវិញ

មនុស្សមានឥរិយាបថចំពោះសង្គម និងបរិស្ថានជុំវិញ គឺជាប្រភេទមនុស្សដែលមានគំនិតស្នេហាមាតុភូមិពិតប្រាកដ មានន័យថា គេមានគំនិតស្នេហាជាតិ ឬកម្រិតជាតិនិយមមោះមុត ហើយចេះផ្សារភ្ជាប់ជីវភាពរស់នៅរបស់ខ្លួនទៅនឹងជីវភាពរបស់មនុស្សជាទូទៅក្នុងសង្គម។ អ្វីទៅដែលហៅថាអ្នកស្នេហាមាតុភូមិពិតប្រាកដនោះ គឺជាជនតស៊ូដើម្បីមាតុភូមិខ្លួន ដើម្បីឲ្យមានឯករាជ្យបរិបូរ មានសន្តិភាព មានសេរីភាព មានលទ្ធិប្រជាធិបតេយ្យពិតប្រាកដរក្សាបាននូវបូរណភាពទឹកដីពេញលេញ ប្រកាន់នូវអព្យាក្រឹតភាព ហើយជានិច្ចកាលប្រឆាំងនឹងអំពើពុករលួយ ការរំលោភសិទ្ធិមនុស្ស ការបំបាត់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ការកេងប្រវ័ញ្ចញើសឈាមប្រជាពលរដ្ឋស្លូតត្រង់ ការបំផ្លាញសម្បត្តិ វប្បធម៌បេតិកភណ្ឌជាតិ និងធម្មជាតិ រួមមានព្រៃឈើ មច្ឆាជាតិ និងសម្បត្តិក្នុងដី ការបំពុលបរិស្ថានជាដើម...។ ម៉្យាងទៀតការសម្តែងចេញនូវឥរិយាបថចំពោះសង្គម គឺជាការបង្ហាញនូវឥរិយាបថចំពោះសមូហភាព គឺការគោរពសមូហភាពនិងសហគមន៍ព្រមទាំងការបង្ហាញអត្តចរិតជាមនុស្សធម៌ ប្រកបដោយគុណធម៌ មានតម្លាភាព និងសមធម៌ដែលជាគុណសម្បត្តិរបស់មនុស្សជាតិទូទៅតាមរយៈការចេះគួរសម សប្បុរសធម៌ និងសេចក្តីសន្តោសត្រាប្រណី។

### ៤.៣-ការសម្តែងចេញនូវឥរិយាបថផ្ទាល់ខ្លួន

ឥរិយាបថផ្ទាល់ខ្លួន គឺជាសភាពចរិតលក្ខណៈរបស់មនុស្សដែលយល់ដឹងដោយខ្លួនឯងនូវសកម្មភាព ដែលខ្លួនបានប្រព្រឹត្តអំពើល្អ ឬអាក្រក់។ តាមរយៈនេះអត្តចរិតផ្ទាល់ខ្លួនបង្ហាញនូវអាកប្បកិរិយារម្យទម ពោលគឺការយល់ដឹងនូវអំពើណាដែលមិនចុះសម្រុងទៅនឹងសង្គម។ មនុស្សដែលស្គាល់ឥរិយាបថផ្ទាល់ខ្លួន តែងប្រកាន់យកនូវចរិតមួយ

ចំនួនដូចជាចេះវាយតម្លៃខ្លួនឯង (ស្វ័យវាយតម្លៃ) ដោយគតិយុត្តិធម៌ ចេះវិភាគដោយខ្លួនឯងនូវសកម្មភាពដែលខ្លួនបានប្រព្រឹត្ត ចេះធ្វើស្វ័យទិតៀន និងចេះកែលម្អដោយខ្លួនឯង ចេះជួយធុរៈអ្នកដទៃដោយមិនសម្លឹងលើគុណបំណាច់ ហើយចូលចិត្តយកមតិអ្នកដទៃមកពិចារណា...។ ការគោរពខ្លួនឯងក៏ជាអំពើមួយបង្ហាញនូវឥរិយាបថផ្ទាល់ខ្លួន ដូចជាភាពមានទំនុកចិត្តលើសកម្មភាពផ្ទាល់ខ្លួន និងការរៀបចំអាកប្បកិរិយាសមរម្យចំពោះសហគមន៍ និងបរិស្ថានជុំវិញ ។

## សន្និដ្ឋាន

អត្តចរិតរបស់មនុស្ស គឺមានការអភិវឌ្ឍពេញមួយជីវិត មានន័យថា គ្រប់វ័យនៃជនគ្រប់រូបនៅក្នុងសង្គម។ ការបណ្ដុះបណ្ដាលស្មារតីអប់រំល្អ គឺមានន័យថាអត្តចរិតរបស់មនុស្សមានសុជីវធម៌ខ្ពស់ ជាកិត្យានុភាព និងការអភិវឌ្ឍសម្រាប់សង្គមទាំងមូល ។ មជ្ឈដ្ឋានដែលជះឥទ្ធិពលខ្លាំងដល់ការអប់រំចរិតមនុស្ស គឺសង្គម និងបរិស្ថានសង្គម សាលារៀន គ្រួសារ ។

ឯកសារ នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ

### ចំណោទពីរបីចំណែក

ប្រដូចនិទានតែប៉ុណ្ណេះ
ផ្ដួចផ្ដើមមួយឃ្លាជាពាក្យផ្ដាំ
អស់លោកក៏ចេះបានរៀនចាំ
ដូចមានចំណាំចំណោទជូន ។

ទំនុកបុរាណមានប្រាជ្ញា
ទុកឲ្យអ្នកក្រោយដោះសំនួន
ចេះចែងបញ្ហាសាស្ត្រាក្បួន
បើគិតឲ្យមួនគួរមានន័យ ។

ចំណោទជាសត្វបរោខោ
បុរសខុសជ្រុលគ្មានលក់ថ្លៃ(១)
អង្គុយមែកពោធិ៍ស៊ីផ្លែជ្រៃ
ចងគោក្របីទាំងមេកូន ។

បុរសម្នាក់ទៀតឡើងដើមឈើ
ស៊ីផ្អែតបន្តិចភ្លេចគល់សូន្យ
បេះផ្លែខាងលើចែកបងប្អូន
បុរសម្នាក់បានកូនភ្លេចគុណម្ដាយ ។

ចំណោទពីរបីចំណែកនេះ
កុំឆ្ងល់នឹងពាក្យអធិប្បាយ
គួររិះឲ្យជិត កុំគិតឆ្ងាយ
ប្រឹងគិតដោះស្រាយប្រាជ្ញាស្រាប់ ។

**ក្រមង៉ុយ**

(១)ពាក្យត្រឹមត្រូវគឺ ពិន័យ តែនេះតម្រូវតាមសម្ផស្សកាព្យ

# មាតាបិតាពុំមែនជាតុលាការ ពុំមែនជាឆ្មាំគុក គឺជាផ្លូវផ្តល់សម្រាប់បុត្រធីតា (ត)

ហេតុអ្វីបានជាកូនចូលផ្ទះ? ផ្ទះគឺជាទ្រនំដ៏សុខសាន្ត និងជាសម្បត្តិរបស់ពួកគេ ទើបគេមិនបោះបង់ ចុះហេតុម្តេចឡើយពេលកូនប្រព្រឹត្តខុសឆ្គង យើងជាមាតាបិតាបែរជាខឹងសម្បាមិនឲ្យកូនចូលផ្ទះ? អ្នកមានបានគិតទេថា កូននៅជិតដៃអប់រំមិនបានដូចបំណង ចុះទម្រាំកូនឃ្លាតឆ្ងាយបែបអនាថា តើនឹងទៅជាយ៉ាងណា? តើនរណាប្រានកូនឲ្យដេកក្រៅផ្ទះ ឬឲ្យចូលផ្លូវវង្វេង...ហេតុម្តេចឡើយបានជាគេដាច់ចិត្តពីអ្នក ឬក៏អ្នកតែម្តងជាអ្នកឲ្យគេដាច់ចិត្ត។ ម៉្យាងទៀត ហេតុអ្វីបានជាកូន ហៅលោកអ្នកថាពុកម៉ែ។ អ្នកមានបានគិតខ្លួនអ្នកទេថា ពេលជួបអាសន្ន ឬឈឺចាប់ដោយរបួសស្នាមស្រែកឲ្យពុកម៉ែជួយ។ ឯកូនរបស់យើងវិញក៏ដូច្នោះដែរ។ ដោយសារពុកម៉ែជាអ្វី? នេះដោយសារតែមាតាបិតាជាម្លប់នៃជីវិតតែមួយគត់ បើដូច្នេះហើយ ហេតុម្តេចឡើយបានជាបែរថ្កោលទោសកូន ថាអាកូនចង្រៃ អាកូន-បំផ្លាញ...។ល។ ហេតុដូចម្តេចឡើយ បានជាយើងប្រើភ្លើងហិង្សាដុតម្លប់ខ្លួនឯង មិនឲ្យកូនជ្រក ដែលកូនត្រូវការបំផុតនោះ។តើនរណាបង្កើតពួកគេ ឬក៏ពួកគេមកសុំកើត និងបង្គាប់ឲ្យយើងដាក់ឈ្មោះគេបែបនេះ បែបនោះ? គេបង្កើតអ្នក ឬអ្នកបង្កើតគេ?សូមលោកអ្នកមានសេចក្តីក្លាហានឆ្លើយការពិត ព្រោះវាជារឿងពិតរបស់លោកអ្នក។តើនរណាបង្រៀនឲ្យគេចេះលួចគាស់ផ្ទាំងបាយ ហេតុម្តេចបានជាគេចេះគាស់សោផ្ទះ ដោយសារតែយើងបិទមិនឲ្យគេចូលផ្ទះ ឬមិនឲ្យគេទទួលទានបាយ។ សាកល្បងពិចារណា! តើដោយសារតែកំហឹងយកឈ្នះមួយគ្រា ឬក៏ខ្វះការពិចារណារបស់លោកអ្នក ឬក៏យ៉ាងដូច្នេះមែន?គួរឲ្យកើតមានបញ្ហាបែបនេះដែរឬទេ?សូមជម្រាបថានៅសាលារៀន មិនបានបង្រៀន ឬ គ្មានកម្មវិធីសិក្សាបែបនេះឡើយ។ អំពើរបស់យើងបែបនេះហើយដែលបង្កើតលទ្ធផលឲ្យកូនខ្សោយវិចារណញ្ញាណ ។

ឧទាហរណ៍មួយបែបទៀត គឺបង្រៀនកូនដោយចាប់បង្ខំ ដោយហិង្សានូវពាក្យ **កុំឡូឡា** តែដោយកូនមិនព្រមថាតាម ពេលនោះអ្នកមានកំហឹងក៏ស្រែកពាក្យនេះយ៉ាងខ្លាំង ខណៈនេះកូននឹងស្រែកពាក្យនេះសន្ធាប់មកវិញយ៉ាងរំពង សួរថាប្រតិកម្មអវិជ្ជមាននេះបង្កឡើងដោយនរណា និងជាកំហុសរបស់នរណា? តើមាននរណាក្រៅពីអ្នកមិនគឺអ្នកទេឬដែលជាអ្នកបង្កឡើង។ នៅពេលនោះបានទទួលអ្វីខ្លះ គឺផលអវិជ្ជមាន។ ម៉្យាងទៀត មានន័យថាការបង្ហាត់បង្រៀនរបស់អ្នកបានបង្កើតសកម្មភាពក្បត់ខ្លឹមសារ តែក៏ពុំមែនមានន័យថាឲ្យបង្រៀនពាក្យ**ឱ្យប** បែរជាអានឱ្យបៗនោះក៏ទេដែរ គឺបង្រៀនដោយពេញចិត្តដោយក្តីអាណិតស្រឡាញ់ មិនធុញទ្រាន់ មិនមែនជាគូសត្រូវនឹងគ្នាដែលអ្នករៀនចង់ចេះ និងឆាប់ចេះ។

ឧទាហរណ៍ ដាស់តឿនដោយសម្តីសង្កត់តែមិនប្រមាថ ៖ **ឯងត្រូវខំរៀន!រៀនឲ្យពូកែ!**។ បើសម្រាប់លោកអ្នកវិញនឹងងឿងឆ្ងល់ថាឲ្យខំរៀនអំពីអ្វី? រៀនដោយវិធីបែបណា? ចុះចំណែកកូនលោកអ្នកវិញ? ចម្លើយឋិតនៅលើលោកអ្នកវិភាគ។ ឧទាហរណ៍ជាច្រើននេះ សុទ្ធតែមានកើតឡើងពិតក្នុងជីវិតនៃគ្រួសារនីមួយៗ ។

រីឯទង្វើឥរិយាបថដែលកើតឡើងពីកំហឹង ក៏ជាកម្លាំងជំរុញមួយផ្តល់ប្រសិទ្ធភាពនៃខ្លឹមសារទូន្មានផងដែរ។ កូនពិតជាមានការភ័យខ្លាចញ័ររន្ធត់ កាលបើដឹងថាលោកអ្នកខឹងចំពោះពួកគេ។ ដូច្នេះកូនលោកអ្នកច្បាស់ជាត្រៀម

លក្ខណៈខ្លះៗបម្រុងទុក សម្រាប់វេងនូវអំពើហិង្សាណាមួយពីលោកអ្នកមិនខាន។ ដូចនេះអំពើហិង្សាដែលគេឲ្យកូនដឹងនេះ ក៏មិនត្រូវលាក់ដែរ តែបង្ហាញចេញមកឲ្យសមល្មម ដូចជាការប្រើពាក្យសម្តីដែលស្លូវបែបធ្ងន់ ម៉ត់ចត់...តែមានន័យប្រមាថ។ល។ ដែលកូនលោកអ្នកអាចដឹងថា លោកអ្នកអាចដឹងហើយ វាដូចជាបង្អែមបន្ថែមអំបិល ដើម្បីលើករសជាតិឲ្យ កាន់តែ វិសេសទៀត។ ប្រតិកម្មហិង្សាដែលស្តែងឡើងតាមឥរិយាបថដូចជា៖ **ខាំមាត់ ញញធ្មេញ ក្តាប់ដៃ គ្រញែងខ្លួន និយាយចង្អុលមុខ**...វាជាឥរិយាបថ ឬអំពើដែលបង្ហាញសញ្ញាណឲ្យដឹងថា ជាមនុស្សកម្រោល គ្មានសុជីវធម៌ គ្មានភាពថ្លៃថ្នូរ ជាមនុស្សមោហៈ ទោសៈ (ឈ្លើយ)។ សូម្បីទំនាក់ទំនងទូទៅក្នុងសង្គមគេក៏បដិសេធ មិនរាប់រកឬគេចាត់ទុកឥរិយាបថនេះជាមនុស្សបាតសង្គម គួរឲ្យខ្ពើមរអើមបំផុត។ នេះក៏ជាអំពើឆ្ពោះទៅរកជម្លោះ ឬការធ្វើសង្គ្រាមហើយ។ ដូចនេះ គួរគប្បីចៀសវាង ឬកុំបីប្រតិបត្តិធ្វើជាទម្លាប់តាមបែបនេះឲ្យសោះ។

រីឯម៉្យាងទៀត កាលបើកូនប្រព្រឹត្តខុសឆ្គងមិនតាមគន្លងដំបូន្មានហើយ បែរជាអ្នកធ្វើហាក់បីដូចធម្មតា ឬគ្មានអ្វីកើតឡើង។សូមកុំចាត់ទុកថា នេះជាអំពើ**អហិង្សា**របស់លោកអ្នក។ អំពើនេះវាគ្រាន់តែជាសភាពស្ងាត់តែមួយប៉ុណ្ណោះ ទុកបណ្តោយឲ្យហេតុផលអវិជ្ជមានកើតឡើង។ពុំមែនជាអំពើនៃការយកចិត្តទុកដាក់អប់រំតាមបែបអហិង្សានោះឡើយ។ ទន្ទឹមនេះ កូនពុំបានដឹងថាលោកអ្នកជាមាតាបិតា មានអ្វីជួយពួកគេ។ នេះជាការខុសឆ្គងដ៏ធំបំផុតផងដែរ របស់លោកអ្នកជាមាតាបិតា ដែលទុកបណ្តោយឲ្យកូនធ្លាក់ក្នុងផ្លូវអន្ធការ។

**១.៣-ហិង្សាដោយវិធីទណ្ឌកម្មលើរាងកាយ**

តើអ្នកធ្លាប់ជួប នូវព្រឹត្តិការណ៍បែបនេះ ចំពោះបុត្រធីតាដូចម្តេចខ្លះ?

ឧទាហរណ៍៖ - ការវាយដំទៅលើរូបរាងកាយ

- ការបោះបោកសម្ភារៈរបស់កូន
- ការរុញច្រាន កញ្ឆក់គ្រវីគ្រវាត់ ទាត់ធាក់...។ល។និង។ល។

ការវាយដំលើរាងកាយបុត្រធីតា គឺជាការដាក់ទណ្ឌកម្ម វាពុំមែនជាការអប់រំនោះឡើយ ។ អំពើបែបនេះប្រព្រឹត្តឡើងដោយកម្លាំងបាយដែលកើតបន្ទាប់ពីពាក្យសម្តីហិង្សាអស់ប្រសិទ្ធភាព ។ ដោយអាងអំណាចជាម្តាយឪពុក កើតទោសៈខ្លាំង ក៏កើតការវាយដំតាមកំហឹង ។ ទណ្ឌកម្មលើរាងកាយជាការបំបាក់ ធ្វើឲ្យកូនខ្លបខ្លាចចំពោះមុខភ្លាមៗតែប៉ុណ្ណោះ ។ អាចនិយាយបានថា លោកអ្នកអស់មានលទ្ធភាពអប់រំ ។ ការទទួលនូវការឈឺផ្សា មាតាបិតាក្លាយទៅជាអ្នកឃោរឃៅ ។ ភាពឃោរឃៅ កើតឡើងពីសេចក្តីល្ងង់ខ្លៅតែមួយគត់ ។ ដូច្នេះ គួរគិតថាបន្តអំពើខុសឆ្គងនេះ នៅក្នុងគ្រួសារយើងតទៅទៀត ឬប្រសិនគ្រួសារធ្លាប់មានមកហើយនោះ? ។ តើយើងគួរបង្កើតទុកនូវមរតកព្រៃផ្សៃក្នុងគ្រួសារ ឬក៏លាងជម្រះចោល? ។ លោកអ្នកជាមាតាបិតាដ៏ជាទីគោរពកាលបើដឹងថាមានកំហុសហើយ ប្រាកដជាក់មិនប្រព្រឹត្តនូវកំហុសដដែលៗទៀតឡើយ ដើម្បីបានមកជាគ្រួសារមួយមានភាពថ្លៃថ្នូរ។ ពេលវាយកូនតើកូននឹងទទួលបានអ្វីខ្លះ? នុះកូនច្បាស់ជាឈឺ តើលោកអ្នកឈឺដែរឬទេ? លោកអ្នកសប្បាយណាស់ទៅឬ? នៅពេលកូនលូនក្រាប កូនភ័យរន្ធត់ កូនស្រែកថាឈឺណាស់ ខ្លួនប្រាណកូនជោកជាំដោយស្នាមរំពាត់ ឬក៏បែកឈាម ឯទឹកភ្នែកហូរឲ្យហាម កែវភ្នែកដ៏ស្រស់ថ្លា ប្រែក្លាយជាកែវភ្នែកមានសភាពល្អក់ដក់ជាមតែក្តីជូរចត់ បង្ហូរដំណក់ទឹកភ្នែកឈឺផ្សា ជាកែវភ្នែកមានសម្រាបតែយំដោយក្តីឈឺចាប់ប៉ុណ្ណោះ ។

(នៅមានត)

លោក **ផេង កែន** ប្រធានការិយាល័យរដ្ឋបាល
មន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង




## របៀប វិធីផ្ទាល់ខ្លួនរបស់គ្រូក្នុងការបង្រៀន
Le procédé

មុននឹងឈានចូលទៅដល់ប្រធានបទខាងលើ ខ្ញុំសូមបង្ហាញជូនពាក្យនិងឃ្លាមួយចំនួន ពាក់ព័ន្ធនឹងសីលធម៌វិជ្ជាជីវៈ ដែលខ្ញុំនៅចាំបានពីការបង្រៀនរបស់សាស្ត្រាចារ្យពេលដែលខ្ញុំជាគរុសិស្សនៅមហាវិទ្យាល័យគរុកោសល្យផ្នែកខាងជើងនៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៦០។ ក្នុងពេលនោះ សាស្ត្រាចារ្យបានផ្ដល់មេរៀនភាគច្រើនទាំងការសរសេរ ការនិយាយ និងការពន្យល់សុទ្ធសឹងតែជាភាសាបារាំងទាំងអស់ ហើយពេលនេះខ្ញុំសូមប្រែសម្រួលដូចតទៅ ៖

-L’instituteur est un homme á qui l`Etat confie l`instruction des enfants.

-គ្រូបង្រៀន គឺជាមនុស្សម្នាក់ ដែលរដ្ឋប្រគល់ការទុកចិត្ត ក្នុងការបង្ហាត់បង្រៀនកុមារ។

-Ces enfants sont des êtres si chers, si précieux pour la Nation et la Patrie.

-កុមារទាំងនេះ សុទ្ធសឹងជាសត្វលោក ដែលមានតម្លៃយ៉ាងពិសិដ្ឋចំពោះជាតិ មាតុភូមិ។

-Si un employé des autres services néglige son travail ce sont des matériels qui sont lésés.

-ប្រសិនបើនិយោជិតម្នាក់នៃសេវាកម្មផ្សេងៗធ្វេសប្រហែស ឬ ពាយងាយក្នុងការងារ គឺសម្ភារ ឬ ទព្វសម្ភារៈទេដែលត្រូវខូចបង់។

ពាក់ព័ន្ធនឹងចិត្តគរុកោសល្យ ខ្ញុំសូមលើកយកឃ្លាមួយរបស់សាស្ត្រាចារ្យជាភាសាបារាំងមកបកប្រែ និងសុំធ្វើការបកស្រាយជូនដូចតទៅ :

Enseigner peu mais bien បង្រៀនតិច តែបង្រៀនល្អមានន័យថា ចង់ឲ្យលោកគ្រូ អ្នកគ្រូ បង្រៀនយឺតៗខ្លីៗ ហើយតិច តែបង្ហាត់បង្ហាញឲ្យបានច្បាស់លាស់ កុំឲ្យសិស្សភ័ន្តច្រឡំ ឬនៅស្រពិចស្រពិល។

ឃ្លាខាងលើនេះ មានអត្ថន័យប្រហាក់ប្រហែល និង ឃ្លាខាងក្រោម ដែលសាស្ត្រាចារ្យបានស្រង់ពាក្យរបស់គរុកោសល្យវិទូ ជាតិបារាំងម្នាក់ មកបញ្ជាក់ និងពន្យល់ :

-Un boiteux dans un chemin droit arrive avant un coureur qui s’égare.

-មនុស្សប៉ុងពៀចម្នាក់ ដើរតាមផ្លូវត្រង់មកដល់ទីមុន អ្នករត់ម្នាក់ដែលវង្វេងផ្លូវ។

ចង់និយាយថា ការបង្រៀនដោយគ្មាន សៀវភៅកិច្ចតែងការ( cahier de préparation ) គឺចេះតែថាម្ដងយ៉ាងនេះម្ដងយ៉ាងនោះ មិនប្រាកដថា ចង់និយាយពីអ្វីហើយជួនកាលនិយាយវែង លឿនមិនច្បាស់លាស់ សិស្សពុំអាចចាប់បាន ឬ យល់បាន ដែលផ្ទុយពីអ្នកដែលបង្រៀនយឺតៗ មានសៀវភៅកិច្ចតែងការអាចបង្រៀនតាមជំហានច្បាស់លាស់តាមប្លង់ដែលបានរៀបចំទុកជាមុន សិស្សអាចស្ដាប់បានឆាប់យល់ នោះហើយដែលលោកប្រៀបធៀបទៅនឹងជនពិការ

ដើងតាមផ្លូវត្រង់ទៅដល់ទិសដៅមុនអ្នកវត់ដែលវង្វេងផ្លូវ។តែការបង្រៀនយឺតៗនោះក៏ត្រូវប្រមាណទៅនឹងរយៈពេលនៃកម្មវិធីសិក្សាផងដែរ។

## ដូច្នេះហើយ បានជាគរុកោសល្យវិទូនិយាយថា :

ការផ្ទេរចំណេះដឹងឲ្យសិស្សពុំមែនដូចការបញ្ច្រកទឹកចូលក្នុងដបឲ្យឆាប់តែបានពេញនោះទេ។

Les enfants doivent être actifs.La classe doit toujours être vivante. កុមារត្រូវតែសកម្ម ថ្នាក់រៀនត្រូវតែរស់រវើក។ "ក្មេងត្រូវតែសកម្ម ថ្នាក់រៀនត្រូវតែរស់រវើក" នោះពុំមែនបានន័យថា ក្មេងប្រឡែងរុញច្រានគ្នា ស្រែកហ៊ោកញ្ជ្រៀវពេញថ្នាក់ដោយឥតមានវិន័យនោះទេ។ រស់រវើកបែបនេះជាការរស់រវើកអវិជ្ជមាន។ ចង់និយាយថា ជាមួយគ្រូដែលប៉ិនប្រសប់ពន្យល់ និង សួរ សិស្សលើកដៃដណ្ដើមគ្នាចង់ឆ្លើយ។ សិស្សស្វាហាប់ រីករាយ ក្លាហានហ៊ានឡើងទៅមុខក្ដារខៀន តាមការចង្អុលហៅរបស់គ្រូ។ ខាងក្រោមនេះជាប្រធានបទដែលខ្ញុំចង់ជម្រាបជូនលោកគ្រូ អ្នកគ្រូទាំងអស់អំពីរបៀបវិធីផ្ទាល់ខ្លួនរបស់គ្រូក្នុងការបង្រៀន ជាពិសេស លោកដែលជាសិក្ខាបនជារីផ្ទាល់តាមថ្នាក់នៃគ្រឹះស្ថានសិក្សានានាទូទាំងប្រទេស។

ការជម្រាបជូននេះ គឺខ្ញុំគ្រាន់តែចង់រំលែកការចេះដឹងដែលខ្ញុំចងចាំបានកន្លងមក តាមការបង្ហាត់បង្ហាញពីសាស្ត្រាចារ្យមុនៗ និងបទពិសោធន៍ផ្ទាល់ខ្លួនខ្លះៗប៉ុណ្ណោះ។

បុគ្គលិកសិក្សាទាំងអស់ដែលធ្លាប់បង្រៀន ជាពិសេស លោកគ្រូ អ្នកគ្រូ ដែលធ្លាប់បានឆ្លងកាត់ការរៀនសូត្រឆ្លងវគ្គបណ្ដុះបណ្ដាលនៅសាលាគរុកោសល្យ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ឬ រៀននៅមហាវិទ្យាល័យគរុកោសល្យនានាពីសម័យមុនៗក៏ដូចជា សម័យក្រោយ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៩ តែងតែមានបទពិសោធន៍គរុកោសល្យគ្រប់ៗគ្នា គ្រាន់តែច្រើន ឬតិចប៉ុណ្ណោះ។

ថ្វីបើលោកទាំងអស់នោះ ធ្លាប់បានឆ្លងកាត់ការសិក្សារយៈពេលដូចគ្នា នៅសាលាគរុកោសល្យដូចគ្នាក្ដី គុណភាព និងការចងចាំរបស់សិស្សដែលគាត់បង្រៀន ពុំសូវបានផលល្អ ឬចងចាំបានយូរដូចគ្នាទាំងអស់ទេ បើសិស្សទាំងនោះទទួលការបង្ហាត់បង្រៀនពីលោកគ្រូ អ្នកគ្រូខុសគ្នា។ ភាពខុសគ្នានេះ មិនទាន់គិតដល់ឆន្ទៈ ការយកចិត្តទុកដាក់ ឬ មិនយកចិត្តទុកដាក់របស់គ្រូនៅឡើយផងក្នុងការបង្ហាត់បង្រៀនសិស្ស។ <u>**ឧទាហរណ៍**</u> : លោកគ្រូ ២នាក់ ចេញពីមហាវិទ្យាល័យគរុកោសល្យដូចគ្នាទៅបង្រៀននៅគ្រឹះស្ថានសិក្សាមួយជាមួយគ្នា បង្រៀនកម្រិតថ្នាក់ដូចគ្នា គ្រូទាំង ២នាក់នេះមានឆន្ទៈ និងការយកចិត្តទុកដាក់ដូចគ្នា តែមានភាពខុសគ្នាអំពីល្បិច របៀប និងវិធីផ្ទាល់ខ្លួន។

ល្បិច របៀប និងវិធីបង្រៀននោះ ពុំមានចែងក្នុងទ្រឹស្ដីបទទេ គ្រូត្រូវតែឈ្លាសវៃ រកមធ្យោបាយ រកនឹកធ្វើយ៉ាងណាដើម្បីភ្ញោចអារម្មណ៍សិស្ស ដោយរកឃ្លា ឬ ពាក្យដែលជួន រណ្ដំគ្នាខ្លះៗមិនបាច់ដល់ទៅកំណាព្យកាព្យឃ្លោងដែលមានពាក្យចុងជួនត្រឹមត្រូវនោះឡើយ តែបើបានត្រឹមត្រូវវារឹតតែប្រសើរណាស់ទៀត គឺគ្រូត្រូវបង្កើតដោយខ្លួនឯង ឬ ចម្លងអ្វីដែលត្រឹមត្រូវពីសាស្ត្រាចារ្យ គ្រូបង្រៀនមុនៗដែលបាននិយាយ និងសរសេរទុកក្នុងឯកសារណាមួយ។

ពាក្យដែលមានចុងជួន រណ្ដំគ្នា ឬ កំប្លែងធ្វើឲ្យសិស្សចូលចិត្ត និងឧស្សាហ៍ធ្វើលំនឹកដោយយកមកទន្ទេញសូត្រ លេង បង្អួតមិត្តភ័ក្តិ ដែលជាហេតុធ្វើឲ្យពាក្យ ឬ ឃ្លាទាំងនោះនៅថ្មីៗក្នុងខួរក្បាល ឬក្រសៃភ្នែករបស់គេជាប់ជានិច្ច។

(នៅមានត)

លោក **គឹម ប៊ុនសាន** អតីតអនុប្រធាន
នាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡា

# អភិវឌ្ឍរបៀបធ្វើការជាក្រុម

(ត)

## ៣.តើត្រូវធ្វើដូចម្តេចដើម្បីឲ្យក្រុមការងារធ្វើការបានល្អ (How to make the team work well)

ដូចយើងបានលើកឡើងខាងដើមរួចមកហើយថា ក្រុម (Team) គឺជាក្រុមមនុស្សរួមគ្នាធ្វើការឲ្យសម្រេចនូវភារកិច្ចរួម។ ដូចនេះការងារដំបូងដែលក្រុមត្រូវធ្វើគឺបង្កើតនូវភារកិច្ចរបស់ក្រុម (Task for the team) ។ ភារកិច្ចរបស់ក្រុមត្រូវតែជាភារកិច្ចដែលត្រូវបានទទួលការឯកភាពពីសមាជិកក្រុមទាំងមូលមិនមែនជាភារកិច្ចរបស់បុគ្គលណាម្នាក់ដោយឡែក។ បន្ទាប់ពីភារកិច្ចត្រូវបានកំណត់រួចហើយ ត្រូវធានាឲ្យប្រាកដថា មានផែនការមួយដើម្បីធ្វើឲ្យសម្រេចនូវភារកិច្ចនេះ ។ ផែនការត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយឲ្យដល់គ្រប់សមាជិកក្រុម ។ ត្រូវរំលឹកប្រាប់គ្រប់សមាជិកក្រុមនូវភារកិច្ច និងផែនការនេះឲ្យបានទៀងទាត់។

ក្នុងដំណើរការនៃការអនុវត្តផែនការ សមាជិកក្រុមម្នាក់ៗត្រូវតែបានទទួលការអនុញ្ញាតឲ្យចូលរួមយោបល់និងធ្វើការសម្រេច។ ដោយហេតុថា នាយកសាលារមែងខ្លាចបាត់បង់នូវអំណាចត្រួតត្រាផ្ទាល់ដល់លទ្ធផលនោះ ពួកគាត់តែងមានអារម្មណ៍ពិបាកក្នុងការផ្តល់ឱកាសជូនបុគ្គលិក និងគ្រូបង្រៀនរួមចំណែកបញ្ចេញយោបល់និងធ្វើការសម្រេច។ ដោយហេតុនេះពួកគាត់ក៏បាត់បង់គួរឲ្យស្តាយនូវការចូលរួមពីពួកគេទាំងនោះ។ នាយកសាលាត្រូវតែមានជំនឿថា មានបុគ្គលិក និងគ្រូបង្រៀនចូលរួមគំនិតយោបល់ និងធ្វើការសម្រេចច្រើនពេលណា ពួកគេក៏កាន់តែមានការជំរុញឲ្យចូលរួមក្នុងការអនុវត្តកាន់តែច្រើនពេលនោះដែរ។

ប៉ុន្តែជាទូទៅការលើកទឹកចិត្តមនុស្សឲ្យចូលរួមផ្តល់គំនិតនិងធ្វើការសម្រេចក៏មិនមែនជាការងាយស្រួលដែរ។ មាននាយកសាលាជាច្រើនបានជួបប្រទះនូវការលំបាកនេះហើយពោលថា *"បុគ្គលិកនិងលោកគ្រូ អ្នកគ្រូក្នុងសាលារបស់ខ្ញុំមិនចាប់អារម្មណ៍ក្នុងការរួមចំណែកធ្វើការសម្រេចទេ។ ពួកគេចូលចិត្តឲ្យខ្ញុំប្រាប់គេតែម្តងថាតើត្រូវធ្វើអ្វី? "*។ ប្រការដែលនាំឲ្យពួកគាត់មានអារម្មណ៍បែបនោះអាចមកពីមូលហេតុពីរគឺឬមួយមកពីគាត់មិនបានយល់ច្បាស់លាស់ពីភារកិច្ច និងផែនការរបស់សាលា ឬមួយមកពីពួកគាត់មិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើការសម្រេច។ ចំពោះមូលហេតុទីមួយនាយកសាលាត្រូវផ្សព្វផ្សាយនូវភារកិច្ច និងផែនការរបស់សាលាឲ្យបានទូលំទូលាយដល់គ្រប់សមាជិកទាំងអស់ក្នុងសាលា ធានាឲ្យប្រាកដថាពួកគេយល់ច្បាស់ទាំងអស់គ្នា។ ចំពោះមូលហេតុទីពីរ នាយកសាលាគប្បីរៀបចំសកម្មភាពលើកកំពស់សមត្ថភាពវិជ្ជាជីវៈជូនគ្រប់សមាជិកទាំងអស់។ វាអាចជាការអញ្ជើញគ្រូឧទ្ទេសពីក្រៅមកបង្រៀនពួកគេ ប៉ុន្តែវិធីដែលល្អគឺ *បង្កើតនូវបរិយាកាសរៀនក្នុងសាលា* ។ ប្រការនេះ នាយកសាលាគប្បីលើកទឹកចិត្តឲ្យគ្រូបង្រៀនចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក និងរៀនពីគ្នាទៅវិញទៅមក ។ ពួកគេគួរតែត្រូវបានចាត់ចែងឲ្យធ្វើការដោយ ជិតស្និទ្ធជាមួយគ្នា ដោយសហការគ្នា និងដោយអន្តរទំនាក់ទំនង។ បានន័យថា គ្រូបង្រៀនដកស្រង់បទពិសោធន៍ក្នុង ចំណោមគ្នាគេ ស្តាប់គ្នាទៅវិញទៅមកដោយយកចិត្តទុកដាក់ និងគោរពគ្នាទៅវិញទៅមក។ ធ្វើយ៉ាងនេះបាន យើងនឹងកសាងបាននូវបរិយាកាសមួយដែលជំរុញមនុស្សឲ្យខំប្រឹងប្រែងកាន់តែខ្លាំងឡើងក្នុងការរៀនសូត្រពីគ្នា ដើម្បីកែលម្អ ទាំងសមត្ថភាពបង្រៀនទាំងចំណេះដឹងទូទៅ។ ក្នុងសាលារៀនមួយដែលមានបរិយាកាសសិក្សារឹងមាំនោះនាយកសាលានិងគ្រូបង្រៀនត្រូវ ៖

- មានការប្រជុំញឹកញាប់ ទៀងទាត់ ឥតឈប់ឈរដើម្បីផ្លាស់ប្ដូរបទពិសោធន៍គ្នា អំពីវិធីប្រតិបត្តិល្អៗក្នុងការបង្រៀននិងរៀន។

- សង្កេតគ្នាទៅវិញទៅមកលើការបង្រៀននិងការដឹកនាំ។

- បង្រៀនគ្នាទៅវិញទៅមក

- និងធ្វើការរួមគ្នាដើម្បីបង្កើតនូវចក្ខុវិស័យរបស់សាលា បេសកកម្មនិង ផែនការរបស់សាលា និងវិធីអនុវត្តដើម្បីធ្វើឲ្យសម្រេចនូវចក្ខុវិស័យ និងផែនការនេះ។

យុទ្ធវិធីមួយទៀតក្នុងការចលនាគ្រូនិងបុគ្គលិកឲ្យចូលរួមក្នុងការពិភាក្សាក្នុងក្រុមនិងវិធីល្អបំផុតដើម្បីលើកកម្ពស់ការចូលរួមផ្ដល់គំនិតយោបល់របស់ពួកគេគឺផ្ដល់ឱកាសពេញលេញឲ្យគេបញ្ចេញគំនិតរបស់គេនិងស្ដាប់យោបល់គេដោយយកចិត្តទុកដាក់។ បច្ចុប្បន្ននេះ មាននាយកសាលាដែលបានប្រព្រឹត្តនូវកំហុសធ្ងន់ធ្ងរដោយបញ្ឈប់បុគ្គលិករបស់ខ្លួនមិនឲ្យបញ្ចប់នូវអ្វីដែលគេចង់និយាយ។ គឺជាការបញ្ឈប់គេមិនឲ្យបញ្ចេញយោបល់ផ្ទាល់ខ្លួនរបស់គេ។ វាជាគ្រោះថ្នាក់បំផុត *គ្រូបង្រៀននឹងឈប់បញ្ចេញយោបល់!* ពួកគេនឹងលែងមានទំនុកចិត្តថានាយករបស់ខ្លួនពិតជាមានការជឿជាក់លើរបៀបធ្វើការជាក្រុម។ ដោយមានការអត់ធ្មត់ ស្ដាប់គ្រូបង្រៀននិយាយឲ្យចប់នូវការគិតរបស់គេ នោះនាយកសាលានឹងធ្វើឲ្យគ្រូបង្រៀននោះមានអារម្មណ៍មោទនចំពោះខ្លួនឯង ហើយជំរុញគេឲ្យខិតខំចូលរួមបញ្ចេញយោ-បល់ ទៀតនៅពេលក្រោយ។

នាយកសាលាមួយចំនួនត្អូញត្អែរថា គ្រូបង្រៀនខ្លះមានសមត្ថភាពនិងចំណេះដឹងទាប ។ ការឲ្យគាត់ចូលរួមយោបល់ច្រើនពេកគឺជាការខាតបង់ពេលវេលា។ ប៉ុន្តែ ប្រសិនបើគាត់មានចំណេះដឹងនិងសមត្ថភាពទាបនោះ វិធីដែលល្អដើម្បីលើកកម្ពស់សមត្ថភាពគាត់គឺលើកទឹកចិត្តឲ្យគាត់ធ្វើលំហាត់គិត និងយកគំនិតនោះទៅរួមចំណែកក្នុងក្រុម ។ នេះជាវិធីមួយក្នុងការបង្កើនអំណាច (empower) ឲ្យគាត់។

វិធីមួយទៀតដើម្បីឲ្យក្រុមធ្វើការបានល្អគឺចៀសវាងការទិតៀនគ្រូបង្រៀននិងបុគ្គលិកតាមបែបអវិជ្ជមាន និងស្ដីបន្ទោស។ ការទិតៀនគួរតែត្រូវធ្វើឡើងតាមបែបវិជ្ជមាន ស្ថាបនា និងលើកទឹកចិត្តតាមតែអាចធ្វើបាន។ មនុស្សទូទៅតែងមានការរីករាយនៅពេលឮការសរសើរ។ នាយកសាលាជាច្រើនមានការលំបាកក្នុងការសរសើរបុគ្គលិកនិងគ្រូបង្រៀនរបស់ខ្លួន ហើយជាញឹកញយ ជំនួសការសរសើរមន្ត្រីរបស់គាត់ គាត់ពោលសរសើរខ្លួនឯងនៅចំពោះមុខមន្ត្រីរបស់ខ្លួនវិញ។ ប្រការនេះធ្វើឲ្យបុគ្គលិក និងគ្រូបង្រៀនមានអារម្មណ៍ធ្លាក់ទឹកចិត្តហើយជួនកាលអាចឈានដល់ការមើលទៅនាយករបស់ខ្លួនជាគូប្រជែងទៅវិញ។ នាយកសាលាដែលឆ្លាតរមែងឈរនៅពីក្រោយផ្ដល់នូវកិត្តិយសនិងការសរសើរជូនមន្ត្រីរបស់គាត់វិញ។

(នៅមានត)

លោក **អ៊ុច សារីក់**

**ប្រស្នា** :

- ទន្សាយ និងឆ្មា ទម្ងន់ ១០គក្រ
- ទន្សាយ និងឆ្កែ ទម្ងន់ ២០គក្រ
- ឆ្កែ និងឆ្មា ទម្ងន់ ២៧គក្រ

តើឆ្កែទម្ងន់ប៉ុន្មាន? ឆ្មាទម្ងន់ប៉ុន្មាន? ទន្សាយទម្ងន់ប៉ុន្មាន?

# របៀបប្រើពាក្យ (ត)

## របៀបប្រើពាក្យ " តាមធម្មតា និង ដូចធម្មតា "

"តាមធម្មតា និង ដូចធម្មតា" ពាក្យទាំងពីរនេះគេប្រើជាកិរិយាមានរបៀប ប្រើក្នុងប្រយោគផ្សេងៗពីគ្នាដូចនេះ:

១- **តាមធម្មតា** ច្រើនប្រើនៅដើមប្រយោគ.ឧ.តាមធម្មតាខ្ញុំទទួលទានបាយល្ងាចនៅម៉ោង៧។ឧ.ឱសថស្ថាន តាមធម្មតា គេតែងតែបើក៦ថ្ងៃទេក្នុងមួយសប្ដាហ៍។ ប៉ុន្តែមានម្ដងៗគេបើកនៅ ថ្ងៃអាទិត្យដែរ។

២- **ដូចធម្មតា** ច្រើនតែប្រើនៅចុងប្រយោគ។ ឧ.ខ្ញុំសុខសប្បាយដូចធម្មតា។

## របៀបប្រើពាក្យ ផ្ទុះ - ខ្ទុះ

ពាក្យទាំងពីរម៉ាត់នេះមានន័យផ្សេងពីគ្នាទាំងស្រុង តែបើគេមិនបានជាគិតដល់ន័យរបស់ពាក្យទាំងពីរនោះទេ មុខជាមានការភាន់ច្រឡំក្នុងការនិយាយគ្នាទៅវិញទៅមកជាមិនខាន ដូចយើងធ្លាប់ឮនូវការប្រើពាក្យផ្ទុះ និង ខ្ទុះ នេះជាញឹកញយ។

ឧ.យប់មិញខ្ញុំបានឮសូរកាំភ្លើងខ្ទុះនៅភូមិខាងត្បូង។

ចំពោះឃ្លានេះគេមិនត្រូវប្រើពាក្យខ្ទុះទេ ព្រោះខ្ទុះជានាមសព្ទ។ គប្បីប្រើពាក្យផ្ទុះ ជាជំនួសវិញ ទើបត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ខ្មែរ។

ដើម្បីបំបាត់ទម្លាប់និយម ឬគ្រាមភាសា ជួយទ្រទ្រង់ និងពង្រីកវប្បធម៌ជាតិឲ្យរឹងរិតតែមានរស្មីត្រចះត្រចង់លើឆាកអន្តរជាតិទៀតនោះ ខ្ញុំសូមធ្វើការបញ្ជាក់នូវរបៀបប្រើពាក្យទាំងពីរម៉ាត់នេះដូចតទៅ :

- **ផ្ទុះ** : កិ- បែកលាន់ឮសូរខ្លាំង។ ឧ-រំសេវផ្ទុះ- កាំភ្លើងផ្ទុះ- គ្រាប់បែកផ្ទុះ ។ល។ ពាក្យផ្ទុះនេះជាអកម្មកិរិយា ( verbe intransitif) ។
- **ខ្ទុះ** : ន- ឈាមកកខាប់ សឬក្រហម ដែលកើតឡើងនៅមុខដំបៅ ឬមុខរបួស។

ឧ.ខ្ទុះបូស - ខ្ទុះដំបៅ ។ល។

ហេតុនេះយើងត្រូវប្រុងប្រយ័ត្នក្នុងការប្រើពាក្យ ឲ្យបានត្រឹមត្រូវ ជាលាយលក្ខណ៍អក្សរក្ដី ជាភាសា និយាយក្ដី ដើម្បីឲ្យពន្លឺអក្សរជាតិយើងមានវឌ្ឍនភាពជាលំដាប់ទៅអនាគត។ម៉្យាងទៀតមានពាក្យខ្លះដូចជា ខ្យល់-ស្នង -ខ្យង-ផឹក-កន្ទេល។ល។ ច្រើននិយាយថា : ខ្យល់ជា ( ខ្វល់ ឬ ខ្យល់ ) -ស្នងជា ( ខ្នង )- ខ្យងជា ( ខ្វង )-ផឹកជា ( ផក់ ) -កន្ទេលជា ( កន្ទើល )។

**កំណត់សម្គាល់** : ពាក្យខ្វល់ ឬ ខ្យល់-ខ្នង-ខ្វង-ផក់-កន្ទើលគ្មានប្រើទេ។

- **ផ្ទុះ** ( Exploser)
- ខ្ទុះ (Le pus)

# ពាក្យត្រូវដឹង

-ពាក្យ **នរ** ប្រែថា ជន មនុស្ស។ ពាក្យ **ឧត្ដម** ប្រែថា ប្រសើរលើស។ ផ្សំគ្នាជា **នរោត្ដម** អានថា នរោតដំ ប្រែថា អ្នកប្រសើរលើសជននានា។ ព្រះបរមនាមនៃព្រះមហាក្សត្រជាអម្ចាស់ជីវិត ជាព្រះរាជអយ្យកោនៃព្រះ**នរោត្ដម សីហនុ** ។

# ពាក្យត្រូវចាំ

អក្សរ " ប " កាលណាមានជើង ្ដ (ជើងដ) - ្ល (ជើងល) - ្រ (ជើងរ) នៅពីខាងក្រោមតែងតែប្រែសំឡេង ទៅជា " ប៉ " ដោយខ្លួនឯងមិនចាំបាច់ប្រើ មូសិកទន្ដ ( ៉ ) ទេ។ ដូចជា ប្ដី ប្លម ប្លន់ ប្រពន្ធ។ ហើយវានាំអក្សរឃោសៈ ទាំងឡាយឲ្យមានសំឡេងតូចតាមខ្លួនជានិច្ច។

ឧ. ប្រមាថ (ប្រម៉ាត) មើលងាយ។

- ប្រមាទ (ប្រម៉ាត) ធ្វេសប្រហែស។

លោក **ចែម ផាន**

អតីតអធិការបឋមសិក្សាជំនាន់ទី១

ការ ថែរក្សា ការពារ អភិរក្ស និងអភិវឌ្ឍន៍ បេតិកភណ្ឌវប្បធម៌ជាតិ ជាកាតព្វកិច្ចកូនខ្មែរទាំងអស់គ្នា ពីព្រោះថាបេតិកភណ្ឌវប្បធម៌ជាតិមានតម្លៃមហាសាលមិនអាចកាត់ថ្លៃបាន ដូចដូនតាខ្មែរបុរាណបានចារបណ្ដាំជាសិលាចារឹកនៅតាមប្រាសទជាច្រើនទុកសម្រាប់ឲ្យកូនចៅជំនាន់ក្រោយជួយថែរក្សា ការពារសម្បត្តិវប្បធម៌ នោះនឹងទទួលបានពរជ័យ តែបើសិនជនណាបំផ្លាញវិញនោះនឹងទទួលបណ្ដាសា វិនាសហិនហោច ដូចខ្លឹមសារនៃសិលាចារឹកមួយបញ្ជាក់អត្ថន័យនេះថា: " **បើសិនមនុស្សទាំងឡាយណាថែរក្សាប្រាសាទ ព្រះបដិមា និងទ្រព្យសម្បត្តិប្រាសាទ នឹងទទួលបាននូវសេចក្ដីសុខចម្រុងចម្រើននៅឋានសួគ៌ ក៏ប៉ុន្ដែបើជនទាំងឡាយណាបំផ្លាញស្នាដៃនេះនឹងធ្លាក់ទៅក្នុងសេចក្ដីវិនាសអន្ដរាយចុះនរក និងត្រូវរន្ទះបាញ់** " ៕



សិលាចារឹកភ្នំព្រះនេត្រព្រះ (K.21១ ខេត្តបន្ទាយមានជ័យ

# សាលាធនធានជួយបង្កើនគុណភាពអប់រំនៅកម្ពុជា(ត)

## III- អគារធនធានមធ្យមសិក្សា

គម្រោង អភិវឌ្ឍវិស័យអប់រំ ដែលឧបត្ថម្ភដោយធនាគារអភិវឌ្ឍអាស៊ី នឹងសាងសង់ អគារធនធានមធ្យមសិក្សាទូទាំងប្រទេសចំនួន ៣៦ ហើយថ្ងៃអនាគត នឹងសាងសង់មួយខេត្តឲ្យបានពីរ។ សព្វថ្ងៃនេះអគារនេះបានសាងសង់រួចចំនួន ១៨ហើយ ដែលបានផ្តល់ប្រយោជន៍ច្រើនដល់វិស័យអប់រំ ។

### ក-តួនាទី និងភារកិច្ចរបស់អគារធនធាន

តាមសេចក្តីណែនាំរបស់ក្រសួងអប់រំយុវជន និងកីឡាលេខ០៦ អយក.សណន ចុះថ្ងៃទី១៤ មករា ២០១០ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់សាលាធនធានដែលមានដូចជា៖

- នាំមុខសាលាដទៃក្នុងការអនុវត្តគោលនយោបាយ គោលការណ៍ កម្មវិធីសិក្សា និងលិខិតបទដ្ឋាននានារបស់ក្រសួងអប់រំ

- ពង្រឹងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចល្អលើការគ្រប់គ្រងប្រើប្រាស់ធនធានមនុស្ស ថវិកាសម្ភារៈនិងពេលវេលារបស់សាលាដោយបើកទូលាយឲ្យសាលាបណ្តាញមានឱកាសធ្វើសកម្មភាពចែករំលែកនូវបទពិសោធន៍ការអភិវឌ្ឍធនធានមនុស្សសំដៅជានាបានគុណភាព និងប្រសិទ្ធភាព។

- អភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនទាំងផ្នែកចំណេះដឹង ជំនាញបច្ចេកទេសផ្នែកចិត្តគរុកោសល្យតាមស្តង់ដាគ្រូក្នុងតំបន់អន្តរជាតិ ទាំងសាលាធនធាន និងសាលាបណ្តាញជាពិសេសផ្តោតលើភាសាអង់គ្លេស ICT សកម្មភាពអនុវត្តកម្មវិធីសិក្សាគោល សមត្ថភាពសិក្សាស្រាវជ្រាវ។

- ពង្រឹងសមត្ថភាពស្វ័យវាយតម្លៃសមិទ្ធផលសិក្សារបស់សិស្ស សាលារៀន សមត្ថភាពវាយតម្លៃ សាលារៀនដើម្បីប្រែក្លាយសាលារៀនទៅជាមណ្ឌលឧត្តមភាពនៃការបង្រៀន និងរៀន។

- ពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនសំដៅឲ្យគ្រូទាំងអស់មានឥរិយាបថ អាកប្បកិរិយាវិជ្ជមានមនសិការវិជ្ជាជីវៈខ្ពស់ មានសីលធម៌ល្អសមជា មាតាបិតាទី២ ឬអាណាព្យាបាលរបស់សិស្ស។

- បង្កលក្ខណៈឲ្យសិស្សបានបន្តការសិក្សាដោយសមធម៌ តាមរយៈការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនិងសិស្សដែលរៀនពូកែ សិស្សកំព្រា សិស្សពិការ សិស្សជនជាតិភាគតិច សិស្សស្រី និងសិស្សស្ថិតក្នុងគ្រួសារមានវិបត្តិ។

- ពង្រឹងការចូលរួមអភិវឌ្ឍ និងគ្រប់គ្រងសកម្មភាពទាំងក្នុង និងក្រៅសាលារៀនរបស់សិស្ស ការចូលរួមពីសហគមន៍ជាតិ អន្តរជាតិ មាតាបិតា អាណាព្យាបាលសំដៅឲ្យមានតម្លាភាព និងសុពលភាព។

- ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិក្នុងគោលដៅធានា និរន្តរភាពរបស់អគារធនធានឲ្យកាន់តែល្អប្រសើរឡើងនូវការសិក្សា ការបង្រៀន និងការសិក្សាស្រាវជ្រាវ។

- ផ្តល់ឱកាសឲ្យសហគមន៍ចូលរួមសហការទទួលខុសត្រូវ និងគ្រប់គ្រងប្រើប្រាស់ថវិកា កសាងផែនការអភិវឌ្ឍសាលារៀន ការអនុវត្តផែនការអភិវឌ្ឍសាលារៀន និងការអនុវត្តយុទ្ធសាស្រ្តវិស័យអប់រំ។



(អគារធនធាននៅវិទ្យាល័យហ៊ុនសែនឈូក ខេត្តកំពត ដាក់ឲ្យប្រើប្រាស់ឆ្នាំ២០១៣)

**ខ-សម្ភារៈបរិក្ខារ**

១-បន្ទប់កុំព្យូទ័រ

បំពាក់ដោយកុំព្យូទ័រចំនួន១៦គ្រឿង បន្ទប់កុំព្យូទ័រនីមួយៗនៃបន្ទប់កុំព្យូទ័រទាំងពីរ ដែលស្ថិតនៅជាន់ផ្ទាល់ដី ផ្ដល់ជូនសិស្ស និងគ្រូនូវលទ្ធភាពប្រើប្រាស់បរិក្ខារ និងសម្ភារៈពហុព័ត៌មានដើម្បីលើកស្ទួយការរៀន និងការបង្រៀន ។ ម៉ាស៊ីនត្រជាក់ត្រូវបានបំពាក់ជូន ដើម្បីធានានូវបរិស្ថានសិក្សាមួយស្អាត និងប្រកបដោយផាសុកភាព ។ គ្រូអាចប្រើកុំព្យូទ័រ ដើម្បីរៀបចំកិច្ចតែងការបង្រៀន ឯកសារបង្រៀន បទបង្ហាញ និងឯកសារផ្សេងៗទៀត។ ទាំងអស់នេះនឹងជួយឲ្យសិស្សប្រើប្រាស់កុំព្យូទ័រប្រកបដោយប្រសិទ្ធភាពសម្រាប់ការសិក្សាក៏ដូចជាការស្រាវជ្រាវ។ ទន្ទឹមនឹងនេះកុំព្យូទ័រជួយឲ្យសិស្សអាចប្រើសម្ភារៈពហុព័ត៌មាននានាដូចជា CDROMs និង DVDs សម្រាប់ការសិក្សារបស់សិស្សពួកគេអាចប្រើប្រាស់សម្ភារៈទាំងអស់នោះសម្រាប់ការស្រាវជ្រាវ ការសរសេរកិច្ចការ។ សម្ភារៈទាំងអស់នោះក៏អនុញ្ញាតឲ្យសិស្សសិក្សាដោយខ្លួនឯង។ ម្យ៉ាងទៀត កុំព្យូទ័រអាចរួមចំណែកដល់អាជីពរបស់សិស្ស បន្ទប់កុំព្យូទ័រនីមួយៗ មានគ្រូបង្រៀនជំនាញកុំព្យូទ័រ និងគ្រូជំនួយ។

(នៅមានត)

លោក **គួយ សុគាន**

# ការតាក់តែងប្រធានចំណោទដោយផ្ដើមចេញពីព័ត៌មាន និងសំណួរ

**វត្ថុបំណង**
- ចេះធ្វើប្រមាណវិធីបូក និងគុណ។
- អានតារាងព័ត៌មាន។

## I.គោលបំណងរបស់សលាកប័ត្រ

-នាំសិស្សឲ្យចេះវិភាគ ពិចារណាលើន័យនៃព័ត៌មានជាអក្សរ និងជាលេខនៅក្នុងតារាង។

-ហ្វឹកហាត់សិស្សឲ្យស្រាវជ្រាវរកអត្ថបទចំណោទមួយដែលទាក់ទងនឹងព័ត៌មានជាអក្សរនិងលេខព្រមទាំងសំណួរដែលមាននៅក្នុងតារាង។

**ចំណោទ**

**តារាងតម្លៃជួល**

| រាយមុខវត្ថុ | មនុស្សចាស់ | កុមារ ១០-១៧ឆ្នាំ | កុមារក្រោម១០ឆ្នាំ |
|---|---|---|---|
| ប៉ោអ៊ីបត់ | ២៥០០៛ | ១៥០០៛ | ១០០០៛ |
| ឆត្រជ្រកម្លប់ | ១០០០៛ | ១០០០៛ | ១០០០៛ |
| ពោងហែលទឹក | ១៥០០៛ | ១០០០៛ | ៥០០៛ |
| ម៉ូតូទឹក ១ម៉ | ៣០០០០៛ | ២០០០០៛ | ១០០០០៛ |

តម្លៃតូប : ៥០០០៛ ក្នុងមួយថ្ងៃ

តើគ្រួសារពូម៉ៅចំណាយប្រាក់ប៉ុន្មាន ?

## II.ការរៀបចំរបស់គ្រូ

ចម្លងតារាងនេះដាក់ក្ដារខៀនមុនពេលបង្រៀនឬសរសេរលើក្រដាសផ្ទាំងធំ (បើមានលទ្ធភាព)។

## III.លំនាំនៃការបង្រៀន

ដំណាក់ទី១ : អំណាន និងការយល់អត្ថន័យ

-ឲ្យសិស្សអានតារាងលើក្ដារខៀនដោយស្ងៀមស្ងាត់។

-ទុកពេលគ្រប់គ្រាន់ឲ្យសិស្សអាន។

-គ្រូសួរ : "តើតារាងនេះ គេនិយាយអំពីអ្វី?"

-ឲ្យសិស្សឆ្លើយឲ្យបានច្រើននាក់ដោយសំដីរបស់គេផ្ទាល់

**ជំណាក់ទី២ : ការស្រាវជ្រាវរបស់សិស្ស**

-ឲ្យសិស្សសាកល្បងដោះស្រាយចំណោទជាបុគ្គលលើក្រដាសព្រាង។

-ទុកពេល ៣ ទៅ ៤នាទី ឲ្យសិស្សដោះស្រាយចំណោទ។

-គ្រូដើរមើលការងារសិស្ស ដើម្បីកត់សម្គាល់សិស្ស ២ ឬ ៣នាក់ ដែលបានធ្វើប្រមាណវិធី និងសិស្សម្នាក់ ឬ ២នាក់ ដែលបានយល់ថា ខ្លួនគេមិនអាចដោះស្រាយបាន។

**ជំណាក់ទី៣ : ការបូកសរុប**

-ជាដំបូង ត្រូវឲ្យសិស្សដែលបានធ្វើប្រមាណវិធីឡើងបកស្រាយពន្យល់(ប្រសិនបើពួកគេពុំទាន់ធ្វើកិច្ចការរួច គ្រូត្រូវសួរសិស្សអំពីអ្វីដែលពួកគេនឹងធ្វើ)។

-បន្ទាប់មក គ្រូឲ្យសិស្សដែលបានយល់ថា គេពុំអាចដោះស្រាយចំណោទបាន ឡើងបកស្រាយពន្យល់ដល់ថ្នាក់រៀនទាំងមូល(គេមិនអាចដោះស្រាយចំណោទនេះបានទេ ពីព្រោះគេខ្វះបម្រាប់ផ្សេងៗ ឬខ្វះអ្វីមួយ)។

-គ្រូត្រូវធ្វើសំយោគដោយបញ្ជាក់បន្ថែមថា: "សំណួរដែលបានចោទឡើងនេះមិនអាចដោះស្រាយបានទេ ពីព្រោះគេមិនដឹងអ្វីសោះអំពីគ្រួសាររបស់ពូម៉ៅ។ដូច្នេះគេត្រូវសរសេរអត្ថបទមួយដែលទាក់ទងនឹងសកម្មភាពផ្សេងៗ ហើយដែលមានការចំណាយរបស់គ្រួសារពូម៉ៅផង ទើបអាចឆ្លើយតបទៅនឹងសំណួរបាន"។

**ជំណាក់ទី៤ : ការណែនាំរបស់គ្រូ និងស្រាវជ្រាវរបស់សិស្សជាបុគ្គល**

-ឲ្យសិស្សតាក់តែងប្រធានចំណោទមួយ ដោយផ្ដើមចេញពីតារាង និងសំណួរខាងលើ។

-ឲ្យសិស្សសរសេរតែចំណុចសំខាន់ៗនៅលើក្ដារឆ្នួន ឬលើក្រដាសព្រាង ប៉ុន្តែមិនបាច់តាក់តែងជាឃ្លោងឃ្លាវែងអន្លាយទេ។

**ជំណាក់ទី៥ : ការបូកសរុប**

-ឲ្យសិស្សតាមក្រុម(២ ឬ ៣ក្រុម) ឡើងអានចំណោទរបស់គេ។

-គ្រូកត់ត្រាបម្រាប់សំខាន់ៗលើក្ដារខៀន។

-ចំពោះចំណោទនីមួយៗដែលសិស្សបានអាន គ្រូត្រូវឲ្យសិស្សទាំងអស់ដោះស្រាយជារួម។

-ចំពោះប្រធានចំណោទណាដែលសិស្សទាំងអស់អាចដោះស្រាយបាន គ្រូត្រូវឲ្យសិស្សនោះអានប្រធានចំណោទម្ដងទៀតឲ្យសិស្សដទៃទៀតស្ដាប់ ដើម្បីពិចារណាលើប្រធាននេះ។

-ចំពោះប្រធានចំណោទណាដែលសិស្សដោះស្រាយមិនចេញ គ្រូត្រូវកែសម្រួល និងបំពេញបន្ថែម ដើម្បីឲ្យក្លាយជាចំណោទពេញលេញ។

**សន្និដ្ឋាន** : ដើម្បីដោះស្រាយចំណោទមួយបាន គេត្រូវមានបម្រាប់ចាំបាច់គ្រប់គ្រាន់។

**សកម្មភាពសម្រាប់ម៉ោងក្រោយ** :

-នៅម៉ោងក្រោយ គ្រូឲ្យសិស្សតាក់តែងចំណោទឡើងវិញឲ្យបានត្រឹមត្រូវតាមក្រុម(៣ ឬ ៤នាក់) ដោយសិស្សធ្វើការប្រុងប្រយ័ត្នក្នុងការតាក់តែងជាអត្ថបទមួយដែលងាយយល់។

-គ្រូប្រមូលចំណោទតាមក្រុមមកកែ។

-គ្រូអាចបិទចំណោទទាំងនោះលើជញ្ជាំងក្នុងថ្នាក់រៀន។

**ជំណាក់ទី៦ : សន្និដ្ឋាន**

-គ្រូធ្វើសំយោគដោយបង្ហាញអត្ថបទ "គួរចងចាំ" ដល់សិស្ស។

**គួរចងចាំ**

ប្រធានចំណោទកសាងឡើងដោយសំណុំព័ត៌មានជាអក្សរ និងជាលេខដែលភ្ជាប់ដោយសំណួរ ឬសំណូមពរ។ ដើម្បីតាក់តែងចំណោទមួយឲ្យបានត្រឹមត្រូវ អ្នកត្រូវហ្វឹកហាត់រកឲ្យឃើញនូវដំណើររឿងដ៏តូចមួយដែលទាក់ទងទៅនឹងព័ត៌មាន និងសំណួរដែលមាន។

## ចម្លើយ

គ្រួសារពូម៉ៅ មានកូន ៣នាក់ ដែលមានអាយុ ១៦ឆ្នាំ ១២ឆ្នាំ និង ៩ឆ្នាំ។ គ្រួសារនេះបានទៅសម្រាកកំសាន្តនៅមាត់សមុទ្ររយៈពេលមួយថ្ងៃ ។ គាត់បានជួលតូបសម្រាកមួយ ។ ម្ដាយជួលប៉ោអ៊ីបត់មួយសម្រាប់អង្គុយលេង។ ឪពុក និងកូនច្បងពីរនាក់ជួលម៉ូតូទឹកជិះលេងម្នាក់មួយៗក្នុងរយៈពេល១ម៉ោង។ កូនពៅជួលពោងហែលទឹកមួយ ។

តើគ្រួសារពូម៉ៅចំណាយអស់ប្រាក់ប៉ុន្មានក្នុងដំណើរកម្សាន្តរបស់គាត់ ?

ដកស្រង់ដោយលោកស្រី **ប៊ុន សារ៉ន**

## ញញឹម

គ្រាន់តែញញឹមមិនខាតអ្វី
ញញឹមស្រស់ស្រាយគ្រប់កាយកល
ញញឹមជូនញាតិគេត្រេកអរ
រាប់អានមិត្តញាតិជាតិខេមរា
ញញឹមនាំមកនូវសប្បាយ
ញញឹមនាំមិត្តច្រើនជុំខ្លួន
ញញឹមនាំស្រាន្តដល់អ្នកព្រួយ
ផ្ដល់កម្លាំងចិត្តអ្នកមានទុក្ខ
ញញឹមសាងនូវក្ដីរាប់អាន
ស្មើសុភមង្គលភ្លឺ

ញញឹមប្រឹមប្រិយមានមង្គល
រាសីនិមលខ្ពស់ជតា ។
ថាយើងចិត្តល្អមានមេត្តា
អ្នកភូមិផងគ្នាជាបងប្អូន។
សុខាគ្រប់កាយផុតស្រពោន
ញញឹមសមសួននាំក្ដីសុខ។
ញញឹមនឹងជួយអ្នកអផ្សុក
ជារស្មីសុខដល់អ្នកឈឺ ។
នាំញាតិលំអានជួបពន្លឺ
ញញឹមប្រសើរនាំមង្គល ។

**អនាមិក**

***




## កតញ្ញូតាធម៌ (តចប់)
## (បទភាកគតិ)

ទេព្ដាគេខឹង ព្រោះខ្លួនរឹងត្អឹង អាងបុណ្យបុព្វេ
ទោសបច្ចុប្បន្ន ជិះជាន់ឥតល្ហែ ភ័ព្វព្រេងបុព្វេ
បើមានក៏ផ្អាក ។

ទោសរមើលគុណ រារាំងមុខបុណ្យ ព្រេងឲ្យសម្រាក
បង្អង់ឈប់សិន បាបថ្មីវិបាក ឲ្យផលឥតស្រាក
ព្រោះបានឱកាស ។

បុណ្យបាបចាស់ថ្មី តែងតែរំពៃ ពុំមែនផ្ដេសផ្ដាស
កាលមានចន្លោះ ត្រូវពេលសស្រាស ហាក់ដូចប្រកាស
ប្រាប់ថាត្រូវអញ ។

ចេញមុខផ្ដល់ផល សុខទុក្ខឲ្យដល់ ជនដែលកកាញ់
កសាងបង្កើត កំណើតជាអញ អញជាសម្លាញ់
ត្រូវអញឲ្យផល ។

វីបុណ្យឬបាប ដែលមានសភាព ជាកម្មតែងផល
សុខទុក្ខឲ្យជន អ្នកធ្វើឲ្យដល់ នូវក្ដីសល់រំលង
ឬក្ដីសុខសាន្ត ។

បាបតែងរារាំង បុណ្យឲ្យនៅគាំង ផ្អាកសិនពុំបាន
ចេញមុខឲ្យផល ជាសុខសម្រាន្ត អ្នកធ្វើតែងបាន
ទទួលរងទុក្ខ ។

បុណ្យក៏រាំង បាបឲ្យនៅគាំង ផ្កាកពុំចេញមុខ
ព្រោះមានឱកាស បុណ្យផ្ដល់ក្ដីសុខ សុទ្ធតែមានមុខ
ទីទៃពីគ្នា ។

ហេតុនោះគួរជន កុំនៅទម្រន់ ក្នុងក្ដីខ្ជិលខ្ជា
គួរកសាងបុណ្យ មានគុណមហិមា ទើបបានឈ្មោះថា
អ្នកស្រឡាញ់ខ្លួន ។

សង្ខេបសេចក្ដី សូមជនប្រុសស្រី បានសុខផ្លូនៗ
ប្រាសចាកទុក្ខសោក ពេគាក្នុងខ្លួន សតិមាំមួន
ចម្រើនតទៅ ៕

លោក **ជ័យ សយ្យនា** ដកស្រង់ពី
សៀវភៅធម្មជីវិត (ព្រះមហា ម៉ាសារិន វិសុទ្ធា)

# មេអំបៅ និង ដង្កូវ

មេអំបៅថា អាចោរមោហា អាដង្កូវនេះ
រូបរាងអាក្រក់ ក្រខ្វក់អីម្ល៉េះ ក្លិនខ្លួនផ្អាបផ្អេះ
អញខ្ពើមណាស់ណ៎ា។

ទៅណាទៅខោល អាក្រាតននល ជាអនាថា
ម្ដេចក៏គឃ្លើន ព្រហើនអស្ចារ្យ វារលេងលើផ្កា
ផ្កានេះបាត់ក្លិន ។

បៀសចេញឲ្យឆាប់ ខំនៅនឹងស្លាប់ នឹងវិទ្ធកមរិន្ទ
ចិញ្ចឹមជីវិត នឹងផ្កាមានក្លិន ជាតិឯងជាតិហីន
ទៅស៊ីលាមកទៅ ។

ដង្កូវថាយើ ពីម្សិលមិញតើ ភ្លេចភ្លាមហើយចៅ
ស្ទាបខ្លួនទៅមើល ត្រជាក់ឬក្ដៅ សត្វមេអំបៅ
ចេញទៅពីណា ។

ឲ្យដឹងសំនួន សឹមលេងសំនួរ ដៀលតិះតាមការ
កុំអាលត្មះអញ ជាមេជាបា ដូចពាក្យឧបមា
បាចខ្សាច់ប្រាសខ្យល់ ។

**ម៉ុក សំអិក** (កូនសន្ទរវោហា ម៉ុក)

# ការងារកសិកររដូវវស្សា

(បទពាក្យប្រាំពីរ)

-គយគន់វាលស្រែប្រែអារម្មណ៍ រុក្ខជាតិតូចធំស្រស់ត្រកាល
សម្រស់ទឹកដីក្តីត្រអាល ជាដំណាក់កាលរដូវថ្មី ។

-ដើមឆ្នាំរដូវនៅកៀកកិត ពិសាខភ្លៀងពិតជោកជាំដី
ប្រជាកសិករត្រេកអរក្រៃ ឃើញទឹកដក់ថ្មីជ្រាយដីស្រែ ។

-ដំណាំរួមផ្សំមានគ្រប់មុខ ធ្វើក្តោគគុកទាន់ដើមខែ
ជីវិតរីកស្រស់លាស់ហូរហែ រនោចចុងខែស្រែមានទឹក ។

-សត្វកង្កែបហ៊ឹងគឹង្គក់ក្អាត់ ពួកបាណកសត្វយំគគ្រឹក
សប្បាយរីកក់តាមខ្សែទឹក ភ្លៀងច្រើនសន្ធឹកទឹកពេញពោរ។

-ត្រពាំងបឹងបួអូរថ្លុកស្ទឹង ប្រឡាយជំលឿងទឹកប្រឹងហូរ
សភាពស្អុះស្អាប់បានផ្លាស់ប្តូរ អាកាសប្រផូររាល់យប់ថ្ងៃ ។

-កសិករប្រុសស្រីគ្រប់អាត្មា រដូវវស្សាមកដល់ថ្មី
រៀបចំឧបករណ៍គោក្របី ប្រើប្រាស់រាល់ថ្ងៃប្រាំងវស្សា ។

-គប្បីត្រូវមានជាប្រចាំ ប្រើបានយូរឆ្នាំគ្រប់វេលា
នង្គ័លរនាស់គ្រឿងសម្ភារ ទុកដាក់ឲ្យជាជឹងកន្លែង ។

-កិច្ចការប្រញាប់មិនទីមទាម រត់រករវាមឥតគិតក្រែង
ខាតបង់វេលាពិតវែងស្លែង ត្រូវគិតឲ្យវែងគ្រប់ប្រការ ។

-គ្រប់សម្ភារៈស្បៀងគិតឲ្យហ្មត់ ទម្លាប់ប្រាកដពីដូនតា
ខោអាវផ្តេកមុំត្រៀមសព្វសារ ពើជួយជានាដល់ពេលប្រើ ។

-ដំបូងគំនិតគិតពូជធា បំពេញការងារតាមវគ្គស្នើ
ដាក់ជីថែទឹកជាបណ្តើរ ផ្កាលល្អប្រសើរស្រូវលាស់ខ្ចី ។

(នៅមានត)

លោក **ប្រាក់ សាចាត់** អតីតប្រធានការិយាល័យ
អប់រំ យុវជន និងកីឡាស្រុកបន្ទាយមាស(កំពត)



# ពុទ្ធសាសនានៅប្រទេសកម្ពុជា(ត)

កំពង់ទាំងឡាយពីបុរាណកាលនៅកោះក្ដី នៅភូមិភាគដែនដីធំក្ដី នៃអាស៊ីភាគអាគ្នេយ៍ដែលគេបានចូលដល់ ហើយគេបានស្គាល់តាមគម្ពីរនិទ្ទេស ឬតាមបញ្ជីក្នុងផែនទី ប៉្តូឡេមី ឬតាមឯកសារចិននោះ មានដូចខាងក្រោមនេះ ៖

១-នៅប៉េគូប្រទេសភូមា (ពីដើមមន) មានកំពង់ ៣ គឺ តក្កោលៈ ១ តេនស្សរិម ១ វេសុង្គ ១ ។

២-នៅជ្រោយម៉ាឡាយូមានកំពង់ ១ ឈ្មោះ តាំព្រលិង្គៈ ។

៣-នៅដែនដីមាសជាគ្រីសេរបស់គ្រីក ឬនៅកំពែងមាសជាលិន-គិន របស់ចិន ។

៤-នៅកោះស៊ូមាត្រាមានកំពង់ ១ ឈ្មោះ បង្កា ។

៥-កំពង់ អុក អែវ (ខ្លះថា អូកែវ) ជាកំពង់ធំនៅមាត់សមុទ្រនៃប្រទេសកម្ពុជាពីបុរាណ ។

លោកសឺដែសសរសេរនៅក្នុងព្រឹត្តិប័ត្រ Histoire ancienne des Etats hindouisés d' Extrême-Orient ៗ ៖

« កំពង់តក្កោលៈនេះ មានចែងក្នុងគម្ពីរមិលិន្ទបញ្ហា ហើយថាតាំងនៅត្រង់ទីក្រុង តាកួប៉ា (Takuapa) នៅខាងលិចជ្រោយក្រា (Kra) ចិនហៅថា តៀវ-គិវ-លី គឺកំពង់នេះហើយដែលរាជទូតប្រទេសនគរភ្នំ (អតីតកម្ពុជា) បានចុះសំពៅទៅកាន់ប្រទេសឥណ្ឌា កាលពី គ.ស ទី៣ » ។

« កំពង់តាំព្រលិង្គនេះ ចិនហៅតាន់-ម៉ី-លៀវ (Tan-mei-Lieou) តាំងនៅក្នុងតំបន់ លីគោរ (Ligor)មានសិលាចារឹកសំស្ក្រឹត ពី គ.ស ទី ៦ ។ តាមគម្ពីរនិទ្ទេសបាលីលោកហៅកំពង់នេះថា តាម្ពលិង្គៈ ជាក្រុងចាស់កើតក្នុងរវាង គ.ស ទី២ » ។

"កោះស៊ូមាត្រាដូចជាកោះជ្វា ឬសេឡែបដែរ មានព្រះពុទ្ធរូបបុរាណមួយ រចនាបែបអមរាវតីនៅខាងលិចស្រុកប៉ាឡេមបាំង លើទួលសេគុនតាំង។ឯកំពង់បង្កានៅនឹងកោះមួយខាងកើតកោះស៊ូមាត្រា ទំនងជាកំពង់នេះហើយដែលមានសំពៅឥណ្ឌាមកមុនគេ ហេតុដូច្នេះហើយបានជាមានឈ្មោះនិយាយក្នុងគម្ពីរនិទ្ទេសថា កំពង់វង្គៈ (Vanga)"។

" ពិតមែនហើយ មានសិលាចារឹកជាភាសាម៉ាឡេបុរាណ ៣ កន្លែងនៅកោះ ស៊ូមាត្រា ពីរនៅស្រុកប៉ាឡេមបាំង (Palembang) មួយទៀតនៅស្រុក ការាំង ព្រហី (Karang Brahi) ខាងលើស្ទឹងបាតាំង-ហារី (Batang-hari), មានសិលាចារឹកមួយទៀតនៅស្រុកកូតាកបូរ (Kota-Kapur) នៅលើកោះ បង្កា (Banka) ។ សិលាចារឹកទាំង ៤ នេះបញ្ជាក់

ថា ក្នុង គ.ស ៦៨៣-៦៨៦ ស្រុកប៉ាឡេមបាំង ជារាជអាណាចក្រកាន់ពុទ្ធសាសនា រាជធានីឈ្មោះ ស្រិវិជ័យ លោក យី-ត្សិង (Yi-Tsing) ហៅថា ចេ-លី-ហ្វូ-ចេ (Che-li-Fo-che) " ។

នៅមានកំពង់មួយទៀត ដែលបច្ចុប្បន្នឈ្មោះ អុក-អែវ ជាកំពង់ពីបុរាណកាលនៅមាត់សមុទ្រប្រទេសខ្មែរ សម័យនគរភ្នំ ដូចសេចក្ដីដែលលោក ម៉ាល្លឺរេត៍ (L.Malleret) សរសេរថា :

" គេបានដឹងកំពង់ អុក-អែវ ថាជាក្រុងបុរាណនៅមាត់សមុទ្រនៃប្រទេសនគរភ្នំ (Founan) ខាងឈូងសមុទ្រសៀម ជាកំពង់សម្រាប់ធ្វើការទាក់ទងខាងជំនួញតាមផ្លូវសមុទ្រប៉ែកអាស៊ីភាគអាគ្នេយ៍ ព្រមទាំងទៅប្រទេសឆ្ងាយៗ រហូតដល់ឆ្នេរទក្ខិណទិសនៃប្រទេសឥណ្ឌា, កំពង់នៅមាត់ទន្លេគង្គា ឬក៏អាចទាក់ទងរហូតទៅដល់ប្រទេសអ៊ីរ៉ង់ និងសមុទ្រមេឌីតេរ៉ាណេទៀតផង " ។

នៅកំពង់ អុក-អែវ នេះ គេបានរកឃើញបុរាណវត្ថុដែលមានអាយុតាំងពី គ.ស ទី១ ម្ល៉េះ, មានរូបអ្នកស្រុក ទេវរូប ពុទ្ធរូប និងរូបិយវត្ថុជាតិរ៉ូម៉ាំង ជាតិឥណ្ឌា អក្សរព្រាហ្មី គួរនឹងរាប់ថាជាកំពង់បុរាណ ដែលបានទទួលយកវប្បធម៌ឥណ្ឌា សាសនាព្រាហ្មណ៍ ពុទ្ធសាសនា តាំងពីកាលនោះមក ។

ពួកអ្នកប្រាជ្ញទាំងឡាយ ដែលខំរិះរកទីឋានសុវណ្ណភូមិតាមប្រភពនានា ទោះជាគម្ពីរមហានិទ្ទេសក្ដី ទោះជាបញ្ជីផែនទីប៉្តូឡេមីក្ដី ទោះជាឯកសារអ្នកនិពន្ធចិនក្ដី មិនហ៊ានបញ្ជាក់ឲ្យប្រាកដថាទីណាជាសុវណ្ណភូមិទេ ។

លោក ហ្វែរ៉ង់ (G.Ferrand) សរសេរថា "មានវប្បធម៌ឥណ្ឌាចូលមកក្រៅប្រទេសឥណ្ឌា និងឥណ្ឌូណេស៊ី មុនគ្រិស្តសករាជ"។ លោក ប៉េ.ឌុយប៉ុង (P. Dupont) ថា "ពុទ្ធសាសនាជាសាសនាដែលប្រទេសទាំងនេះបានទទួលតាំងពីដើមគ្រិស្តសករាជទី១ម្ល៉េះ ហើយមានជ័យជំនះឈ្នះការភ័ន្តប្រែទាំងខាងផ្លូវនយោបាយ ទាំងខាងផ្លូវឃោសនា ព្រមទាំងមានដំណើរតាំងនៅមាំមួន និងឋិតថេរចេរកាលជាងនៅប្រទេសឥណ្ឌា"។

លោក សឺដែស (G. Coedes) សរសេរថា "ភិក្ខុទិគនាគជាសិស្សព្រះមហាថេរអសង្គៈ ធ្លាប់បានសិក្សានៅមហាវិទ្យាល័យនាលន្ទាអស់រយៈវេលា ៣០ឆ្នាំ ហើយបានទៅសុវណ្ណទ្វីប (កោះស៊ូមាត្រា ឬ ម៉ាឡេស៊ី)។ រាជទូតចិនឈ្មោះ យី ត្សិង (Yi Tsing) ហៅសុវណ្ណទ្វីបថា គិន-លិន ប្រែថា កោះមាស ឬព្រំដែនមាស ហើយថានៅអាណាចក្រ គិន-លិន នេះ គេគោរពព្រះពុទ្ធមានស្រមណ៍ច្រើនពាន់"។

ឯកសារទាំងប៉ុន្មានខាងលើនេះ អាចឲ្យយើងសន្និដ្ឋានថា ពុទ្ធសាសនាដែលផ្សាយចេញពីប្រទេសឥណ្ឌាកាលពីពុទ្ធសតវត្សទី៣នោះ បានទៅនៅឋិតថេរទាំងខាងដែនដីជំឬជ្រោយ គឺសុវណ្ណភូមិផង ទាំងលើកោះធំតូចគឺសុវណ្ណទ្វីបផង ហើយថែមទាំងចម្រើនលូតលាស់ចាប់តាំងពីខាងដើមគ្រិស្តសតវត្សរ៍មកម្ល៉េះ។

(នៅមានត)

ដកស្រង់ពីសៀវភៅ ពន្លឺពុទ្ធសាសនា

រៀបរៀងដោយលោក **សោម ខន**

" ចំណេះវិជ្ជា គឺជាគ្រឿងលម្អ នៅពេលយើងចម្រុងចម្រើន ហើយជាជម្រកនៅពេលក្រលំបាក "

អារីស្តូត ទស្សនវិទូក្រិក

(៣៨៤.៣២២ មុនគ.ស)

# សាលារៀនគឺជាគ្រឹះស្ថានសង្គមមួយ(ត)

- **តម្លៃអន្តរកម្មឯករាជ្យ** ( Value of Interdependence) :

យើងមិនអាចគេចចេញពីទំនាក់ទំនងនៃសង្គមនៅក្នុងជីវិតពិត ។ សង្គមត្រូវតែផ្ដល់នូវស្ថានការណ៍មួយដែលដឹកនាំសិស្សឲ្យដឹងពីទំនាក់ទំនងនៅក្នុងសហគមន៍ប្រទេស និងនៅក្នុងពិភពលោករបស់យើងនេះ ។ លោកបណ្ឌិត K.L.Shrimali បានសង្កេតថា សាលារៀនគួរបង្កើតនូវស្ថានភាពផ្សេងៗ ដើម្បីផ្ដល់នូវការអនុវត្តជានិរន្តរភាពនៅក្នុងសង្គម និងការរស់នៅសហការគ្នា ។ វាត្រូវបានលើកទឹកចិត្តឲ្យធ្វើសកម្មភាពតាមរយៈកុមារដែលជំរុញឲ្យបុគ្គលិកធ្វើសកម្មភាពដោយខ្លួនឯងនៅក្នុងក្រុម សហគ្រាស កិច្ចសហប្រតិបត្តិការណ៍ក្នុងការប្រកួតប្រជែងម្នាក់ៗ។

- **ឱកាសសំរាប់អភិវឌ្ឍដោយពេញលេញចំពោះកុមារ** ( Opportunities for full developmentof the Child) :

នៅក្នុងសាលារៀនបច្ចុប្បន្នគេបានផ្ដោតលើមុខវិជ្ជាសំខាន់ៗ( Subject-Centred)។គោលវិធីសិស្សមជ្ឈមណ្ឌលគឺជាគោលវិធីមួយដែលគេអនុវត្តតាមលក្ខណៈចិត្តសាស្ត្រប៉ុន្តែពុំមានលក្ខណៈឡូស៊ីកប៉ុន្មានទេ( not logical) ។សាលា-រៀនត្រូវតែមានគោលដៅដើម្បីបណ្ដុះបុគ្គលិកលក្ខណៈកម្រិតខ្ពស់ ។ បុគ្គលិកលក្ខណៈរបស់កុមារ គឺជាលទ្ធភាពរបស់បុគ្គលិកម្នាក់ៗ ហើយកុមារត្រូវគេបង្រៀនផ្នែករូបកាយ ចិត្តគំនិត ស្មារតី។ សាលារៀនបែបអភិវឌ្ឍនិយមនិងគោលដៅផ្ដល់ឱកាសឲ្យសិស្សអភិវឌ្ឍផ្នែកទាំង ៣ រូបកាយ ស្មារតី បញ្ញាពោលគឺអភិវឌ្ឍបុគ្គលិកលក្ខណៈ។

- **ការទទួលស្គាល់ភាពខុសគ្នារវាងបុគ្គលម្នាក់ៗ** ( Recognition of Individual differences) :

ភាពខុសគ្នារវាងកុមារម្នាក់ៗត្រូវបានគេវាយតម្លៃនិងផ្ដល់ឱកាសដល់ពួកគេសម្រាប់លូតលាស់ផ្នែកមេត្តាករុ-ណាធម៌សន្ដោសប្រណីសមស្របទៅនិងសមត្ថភាពផ្ទាល់របស់គេ។ វាត្រូវបានគេចងចាំថាគ្មានកុមារ២នាក់ណាដែលមាន លក្ខណៈពីធម្មជាតិដូចគ្នាទាំងអស់នោះទេ។សាលារៀនគួរព្យាយាមផ្ដល់ឱកាសយ៉ាងសមរម្យសម្រាប់សិស្សម្នាក់ៗអភិវឌ្ឍនូវ ឥរិយាបថពីធម្មជាតិរបស់គេតាមរយៈការសិក្សានៅក្នុងសាលារៀន។

- **សេចក្ដីស្រេកឃ្លានលើយុត្តិធម៌សង្គម** ( Passion for Social Justice) :

ប្រទេសឥណ្ឌា គឺជាផ្ទៃដីមួយដែលសម្បូរទៅដោយវណ្ណៈ ជំនឿសាសនាផ្សេងៗ។ សាលារៀនបច្ចុប្បន្ននេះត្រូវតែមានសន្ដានចិត្តអប់រំកុមារចេះសន្ដោសប្រណី និងមានទឹកចិត្តចង់បានភាពយុត្តិធម៌នៅក្នុងសង្គម ដោយផ្អែកទៅលើវិចារណញ្ញាណ ហ៊ានរិះគន់អំពើពុករលួយ អំពើអាក្រក់ និងការកេងប្រវ័ញ្ចរបស់សង្គម។

- **ការទទួលខុសត្រូវសំរាប់អប់រំសីលធម៌** ( Responsibility for moral education) :

ក្នុងសម័យអតីតកាល ការអប់រំសីលធម៌ត្រូវបានគេផ្ដល់ឲ្យតាមរយៈព្រះវិហារ និងគ្រួសារ ។ ក្នុងសម័យបច្ចុប្បន្នការអប់រំសីលធម៌ត្រូវគេរៀបចំឡើងតាមសាលារៀន។ ការអប់រំសីលធម៌មានសារៈសំខាន់ណាស់គឺលើកកម្ពស់សមត្ថភាពចរិតលក្ខណៈរបស់មនុស្ស។

- **ការទទួលខុសត្រូវលើការអប់រំវិជ្ជាជីវៈ** ( Responsibility for Vocational Education) :

ប្រព័ន្ធនៃការបណ្ដុះបណ្ដាលអប់រំវិជ្ជាជីវៈនៅក្នុងយុគសម័យបុរាណ និងយុគសម័យកណ្ដាល ( Vocational Education in Ancient and Medieval) ។ ក្នុងសម័យបុរាណ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈត្រូវគេផ្អែកទាំងស្រុងទៅលើគ្រួសារ។ កូនប្រុសរៀនបណ្ដុះបណ្ដាលវិជ្ជាជីវៈដោយអនុវត្តការងារតាមរយៈឪពុក។ បញ្ហាសេដ្ឋកិច្ចសង្គមដ៏ស្មុគស្មាញ

ពេលបច្ចុប្បន្ននេះ គឺជាប្រព័ន្ធមួយដ៏មានប្រយោជន៍ហើយបានប្រែក្លាយទៅជាភាពចាំបាច់របស់សាលារៀនសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈដល់សិស្ស។

- **សេរីភាពសម្រាប់ខ្លួនឯង** ( Freedom for self-development) :

ដើម្បីអភិវឌ្ឍលើគំនិតច្នៃប្រឌិតរបស់ចិត្តនិងសេរីភាពក្នុងការអភិវឌ្ឍខ្លួនឯង និងសេរីភាពសម្រាប់ធ្វើសកម្មភាពត្រូវ បានគេផ្តល់ឲ្យតាមរយៈសាលារៀន។ សេរីភាពនេះ មិនត្រូវបានគេផ្តល់ឲ្យជាអាជ្ញាប័ណ្ណទេ ប៉ុន្តែគេអាចត្រួតពិនិត្យវាតាមរយៈការរស់នៅរបស់បុគ្គលម្នាក់ៗនៅក្នុងសហគមន៍។សេរីភាពរបស់សិស្សបានមកពីកម្លាំងក្លាហានរបស់សិស្ស និងការលើកទឹកចិត្តផ្នែកខ្លាំងរបស់គ្រូ។ សេរីភាពពិសេសរបស់សិស្សប្រើនៅក្នុងការចូលរួមការសន្តោសប្រណីនិងសមត្ថភាព ដើម្បីអភិវឌ្ឍបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន រួមជាមួយការគ្រប់គ្រងរបស់គ្រូ។

- **ការពេញចិត្តដោយទទូចទៅលើសកម្មភាពប្រតិបត្តិ** ( Satisfaction of the urge for practical activity) :

លោកបណ្ឌិត Zakir Husain បានសង្កេតថា អនាគតនៃសាលារៀនរបស់ប្រទេសឥណ្ឌា នឹងមិនអាចមាននិរន្តរភាពចំពោះសិស្សប្រុស សិស្សស្រីបានទេដោយរៀបចំឡើងតាមរយៈសកម្មភាពដ៏មានថាមពលរបស់សិស្សឲ្យសិស្សអង្គុយស្ងៀមទាំងងឹតងងុល បង្កើតក្តីស្រមៃលើឯកសារផ្សេងៗ និងបង្ខំឲ្យគេទទួលយកចំណេះដឹងទាំងគ្មានឆន្ទៈ។ ចំណែកឆន្ទៈពិតប្រាកដនៃការអប់រំ គឺធ្វើឲ្យសិស្សមានសកម្មភាពទទួលយកចំណេះដឹងតាមបំណងរបស់គេ ។

- **កម្មវិធីសិក្សានៅសាលារៀនត្រូវបានគេមើលឃើញថាជាការឯកភាពគ្នាមួយ** :( Programme of the School Visualise as a Unity)

គណៈកម្មការនៅមធ្យមសិក្សាអប់រំចំណេះទូទៅបានសង្កេតថា យើងមិនអាចឃើញថា សាលារៀនទាំងអស់ធ្វើឲ្យមាននិរន្តរភាពនៃការសិក្សានៅក្នុងថ្នាក់រៀនឡើយ ។ បន្ថែមជាមួយគ្នានេះ ភាពឯករាជ្យដោយមិនទាក់ទងជាមួយកម្មវិធីសិក្សា ខ្លឹមសារមេរៀន និងវិធីសាស្ត្របង្រៀន។ កម្មវិធីសិក្សានៅក្នុងសាលារៀននឹងត្រូវបានគេមើលឃើញថាជាការឯកភាពគ្នា និងលើកទឹកចិត្តតាមរយៈចិត្តសាស្ត្រ។

យើងអាចពិភាក្សាគ្នាបានយ៉ាងល្អិតល្អន់អំពីមុខងារសាលារៀនស្របតាមទស្សនៈរបស់លោកS.Bala Krishna Joshi ដែលលោកបានអះអាងថា សាលារៀនមិនគ្រាន់តែជាសំណង់អាគារប្រក់ក្បឿង និងលាបបាយអររួមជាមួយកម្មវិធីសិក្សាសម្រាប់សិស្ស និងគ្រូបង្រៀនតែប៉ុណ្ណោះទេហើយក៏មិនមែនជាកន្លែងទីផ្សារផ្តល់ចំណេះដឹងនោះទេ តែវាជាកន្លែងនៃការប្រកួតប្រជែងអ្នកដែលមានសមត្ថភាពផ្សេងៗគ្នា។ សាលារៀនក៏មិនមែនជាកន្លែងស្ថានីយ៍រទេះភ្លើងដែលប្រមូលផ្តុំមនុស្ស និងសម្ភារៈឡើយ។ សាលារៀនមិនមែនជាកន្លែងសម្រាប់អប់រំអ្នកទោសក្មេងៗនោះទេ។ សាលារៀន ជាកន្លែងបណ្តុះសរីរាង្គ ស្មារតី និងបុគ្គលិកលក្ខណៈរបស់មនុស្ស។ សាលារៀនគឺជាមជ្ឈមណ្ឌលសហគមន៍ដ៏រស់រវើក បណ្តុះបណ្តាលជីវិតឲ្យមានភាពភ្លឺចិញ្ចាចចិញ្ចែង និងថាមពល។ សាលារៀនគឺជា ភូមិគ្រឹះដ៏អស្ចារ្យមួយដែលបណ្តុះមូលដ្ឋានគ្រឹះនៃកេរ្តិ៍( goodwill) របស់សិស្ស កេរ្តិ៍ឪពុកម្តាយ។ ចំណែកឯ ពាក្យសាលារៀនល្អ គឺជាគេហដ្ឋានដ៏មានសុភមង្គលជាចេតិយដ៏ពិសិដ្ឋ ជាមជ្ឈមណ្ឌលសង្គម និងជាផ្ទាំងទស្សនីយភាពដ៏ល្អប្រសើរមួយ។

**ឃ-សាលារៀនជាមជ្ឈមណ្ឌលនៃសេវាសហគមន៍**( School as a centre of Community Service)

លោក Branford បានសរសេរអំពីការអប់រំដែលមានចំណងជើងថា ទិន្នន័យ និងគោលការណ៍ដំបូងរបស់គេ។ សាលារៀនគួរតែមានសញ្ចេតនា ឬជាគំរូនៃពិភពលោកតែមិនមែនជាពិភពនៃកិច្ចការងារក្នុងពិភពលោកនោះទេ ប៉ុន្តែគេត្រូវនិយាយអំពីការអប់រំមនុស្សធម៌ រូបកាយ ព្រលឹង ក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។

លោក T.M Greene បាននិយាយថា ផ្នែកកម្មវិធីសិក្សានៅសាលារៀនដ៏ល្អមួយដែលបានមកពីតម្រូវការនៃសហគមន៍ ក៏ជាផ្នែកទាំងមូលនៃជីវិតរបស់មនុស្សដែរ។ សាលារៀនគឺជាកន្លែងពន្លឿនឥទ្ធិពលនៃគុណប្រយោជន៍

វប្បធម៌ដើម្បីផ្សព្វផ្សាយក្នុងសង្គម។

លោក Harold Rugg គិតថា សាលារៀនគឺជាសហគ្រាសនៃការរស់នៅរាប់ទាំងសង្គម និងបុគ្គលខ្លួនឯង។

យោងទៅតាមគណៈកម្មការអប់រំនៅមធ្យមសិក្សាចំណេះទូទៅបានបង្ហាញថា សាលារៀនមធ្យមសិក្សាចំណេះទូទៅត្រូវតែទទួលខុសត្រូវដោយខ្លួនឯងលើការផ្តត់ផ្គង់នូវភាពសមរម្យណាមួយដល់សិស្សនិងមុខវិជ្ជាពលរដ្ឋវិជ្ជារួមជាមួយប្រសិទ្ធភាពនៃវិជ្ជាជីវៈ ព្រមទាំងគុណសម្បត្តិនៃអត្តចរិតលក្ខណៈ។ ពួកគេមានលទ្ធភាពអាចបំពេញកិច្ចការលើកកម្ពស់នូវ តម្លៃជាតិសាសន៍របស់គេ។

យោងទៅតាមទស្សនៈ J.S.School ដោយផ្តោតទៅលើភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ ។ ប្រជាពលរដ្ឋគ្រប់រូបគួរតែបណ្តុះបណ្តាលកូនរបស់គេឲ្យមានស្មារតីរីករាយ ប្រសិទ្ធភាពសេវាកម្ម និងក្លាយជាគំរូសម្រាប់សហគមន៍ ។

លោក W.K.Mccharen បានសរសេរថា សហគមន៍សាលារៀនមួយ គឺជាកម្មវិធីសិក្សាដែលត្រូវគេរៀបចំឡើងសម្រាប់ដំណើរការសិក្សារៀនសូត្រដ៏មានប្រសិទ្ធភាព និងមានសារៈសំខាន់ទៅលើផ្នែកខ្លះៗរបស់កុមារដែលអាចជួយលើកកម្ពស់គុណសម្បត្តិនៃការរស់នៅក្នុងសហគមន៍ដោយជួយស្វែងរកអ្វីៗដែលជាតម្រូវការរបស់មនុស្សក្នុងសហគមន៍។

លោកសាស្ត្រាចារ្យ Humayun Kabir បាននិយាយថា សាលារៀនគួរតែឆ្លុះបញ្ចាំងលើជីវិតមនុស្សក្នុងសហគមន៍។ សិស្សសាលានៅក្នុងប្រទេសឥណ្ឌាត្រូវរស់នៅក្បែរប្រជាជនឥណ្ឌាបំផុត ។

លោក (Ivol Stafford) បានសរសេរថា កម្មវិធីសិក្សានៅសាលារៀន និងសហគមន៍គឺជាកម្មវិធីសិក្សាដ៏ល្អមួយដែលបានមកពីសហគមន៍ជាតម្រូវការគ្រប់ផ្នែកទាំងអស់នៃជីវិតមនុស្សក្នុងសហគមន៍។

លោក (K.G.Saiyidain) បានបង្ហាញថា សាលារៀនរបស់មនុស្សត្រូវតែផ្អែកលើតម្រូវការ និងកម្មវិធីដំបូងរបស់មនុស្សដែរ។ កម្មវិធីសិក្សាគួរតែជាខ្លឹមសារសំខាន់ៗដែលទាក់ទងនឹងជីវិតមនុស្ស ហើយវិធីសាស្ត្រនៃការងារត្រូវតែមានលក្ខណៈប្រហាក់ប្រហែលទៅនឹងមនុស្សដែរពោលគឺ ឆ្លុះបញ្ចាំងលើសារប្រយោជន៍ និងចរិតលក្ខណៈនៃជីវិតមនុស្សក្នុងសហគមន៍ និងក្នុងធម្មជាតិ។

ទំនាក់ទំនងគ្នារវាងសាលារៀន និងសហគមន៍ត្រូវបានលោកសាស្ត្រាចារ្យ John Dewey បង្ហាញថាអ្វីដែលល្អបំផុត និងសេចក្តីប៉ងប្រាថ្នារបស់ឪពុកម្តាយចំពោះកូនគេផ្ទាល់ ក៏ជាសេចក្តីប៉ងប្រាថ្នារបស់សហគមន៍ផងដែរ ម្យ៉ាងវិញទៀត សាលារៀនជាកន្លែងដ៏ចង្អៀតមួយដែលសកម្មភាពរបស់វាជួនកាលអាចជាសកម្មភាពបំផ្លាញលទ្ធិប្រជាធិបតេយ្យរបស់យើងទៅវិញ ។

(នៅមានត)

លោក **គួយ សុគាន**
សាស្ត្រាចារ្យវិទ្យាស្ថានជាតិអប់រំ

" បណ្ឌិតរមែងវៀរការដែលមិនមានប្រយោជន៍ កាន់យកតែការដែលមានប្រយោជន៍ "

ពុទ្ធភាសិត




## ប្រព័ន្ធបកតិសំខ្យាខ្មែរ

ការរាប់ចំនួនរាយ ឬលេខរាយ ដែលខ្មែរយើងប្រើប្រាស់មានច្រើនលើសពីតម្រូវការឆ្ងាយណាស់។ តែក៏មានមតិរិះគន់ថា ខ្មែរយើងរាប់មិនដល់ដប់ គឺរាប់បាន មួយ ពីរ បី បួន ប្រាំ ក៏ត្រឡប់សាមក ប្រាំមួយ ប្រាំពីរ ប្រាំបី ប្រាំបួន ទើបដល់ដប់។ តាមពិតការដាក់ពាក្យសម្រាប់ថា ចំនួន ប្រាំមួយ ប្រាំពីរ ប្រាំបី ប្រាំបួន គ្មានពិបាកអីបន្តិចសោះយើងអាចថា ប៊ិក ប៉ុក ម៉ុង ម៉ាំង ដប់ ក៏បានដែរ តែការរាប់ត្រឹមប្រាំ ហើយសាមក ប្រាំមួយ ប្រាំពីរ ប្រាំបី ប្រាំបួន មានអត្ថន័យជ្រាលជ្រៅណាស់ ដែលបុរាណាចារ្យលោកបង្កប់ន័យ ទៅតាមលទ្ធិពុទ្ធសាសនា។ ការរាប់យ៉ាងនេះគឺ លោកចង់បញ្ជាក់ថា ក្នុងភទ្ទកប្បយើងនេះមានព្រះសព្វញ្ញុពុទ្ធ ៥ព្រះអង្គ គឺព្រះកុក្កុសន្ធោ ព្រះកោនាគមនោ ព្រះកស្សបោ ព្រះសមណគោតម និង ព្រះសិអារ្យមេត្រិយ ហើយមកដល់សព្វថ្ងៃនេះព្រះពុទ្ធត្រាស់ដឹងបានបួនព្រះអង្គហើយនៅឡើយព្រះសិអារ្យមេត្រិយ។

នៅក្នុងអភិធានប្បទីបិតាបាឋ : លោកបានពន្យល់ពីរបៀបរាប់រហូតដល់អសង្ខេយ្យយ៉ាងនេះថា៖

១០ រយ ស្មើ ១ ពាន់,
១០ ពាន់ ស្មើ ១ម៉ឺន
១០ ម៉ឺន ស្មើ ១ សែន,
១០ សែន ស្មើ ១ លាន
១០ លាន ស្មើ ១ កោដិ,
១០ កោដិ ស្មើ ១ បកោដិ
១០ បកោដិ ស្មើ ១ កោដិបកោដិ,
១០ កោដិបកោដិ ស្មើ ១ នហុត
១០ នហុត ស្មើ ១ និន្នហុត,
១០ និន្នហុត ស្មើ ១ អក្ខោភិនី ឬអក្ខោហិណី
១០ អក្ខោភិនី ស្មើ ១ ពិន្ទុ,
១០ ពិន្ទុ ស្មើ ១ អព្វុទៈ
១០ អព្វុទៈ ស្មើ ១ និរព្វុទៈ,
១០ និរព្វុទៈ ស្មើ ១ អហហៈ
១០ អហហៈ ស្មើ ១ អដដ ឬ អដដ្ឋៈ,
១០ អដដ ស្មើ ១ អពពៈ
១០ អពពៈ ស្មើ ១ សោគន្ធិក,
១០ សោគន្ធិក ស្មើ ១ ឧប្បលៈ
១០ ឧប្បលៈ ស្មើ ១ កុមុទៈ,
១០ កុមុទៈ ស្មើ ១ បទុមៈ
១០ បទុមៈ ស្មើ ១ បុណ្ឌរិក,
១០ បុណ្ឌរិក ស្មើ ១ កថានៈ
១០ កថានៈ ស្មើ ១ មហាកថានៈ,
១០ មហាកថានៈ ស្មើ ១ អសង្ខេយ្យ។

ឈ្មោះចំនួនដែលរាប់ខាងលើនេះធំតូច ជាងគ្នាដប់ៗដង បើគិតជារួម ១ អសង្ខេយ្យ មានសូន្យតែ ២៤ ទេ (១ ០០០ ០០០ ០០០ ០០០ ០០០ ០០០ ០០០ ០០០) ។ តែបើតាមការពន្យល់ពាក្យរាប់ចំនួនដែលមានក្នុងវចនានុក្រម សម្ដេច ជួន ណាត ឃើញថា ឈ្មោះចំនួនធំតូចជាងគ្នាមួយរយសែនដង ហើយឈ្មោះខ្លះក៏បញ្ច្រាសបណ្ដោយគ្នាទៀត។ ក្នុងវចនានុក្រមពាក្យថាអសង្ខេយ្យមានន័យថាឈ្មោះ សំខ្យាចំនួន មួយរយសែនមហាកឋាន (មាន ១៤០ សូន្យ)ច្រើនរាប់ពុំបានស្មានឬប្រៀបប្រដូចពុំកើត...។

យោងតាមឯកសារខ្លីមួយដែលគេប្រទះឃើញដម្កល់ទុកនៅបណ្ណាល័យអាឡាំងសុងនាប្រទេសបារាំងសរសេររៀបរៀង ដោយ ហ្លួងពិភក្ដិជានី ចុងសតវត្សទី១៧ ស្ដីពីការរាប់ចំនួនមានសរសេរថា (សរសេរតាមអក្ខរាវិរុទ្ធថ្មីយើង) ៖

" *រឿងរាប់ប៉ុន្មានឲ្យដឹង ១០ពាន់មួយម៉ឺន,១០ម៉ឺន១សែន,១០សែន១លាន,១០លាន១កោដិ,មួយរយសែនកោដិថា១បកោដិ,មួយរយសែនបកោដិថា១កោដិប្បកោដិ,មួយរយសែនកោដិប្បកោដិថា១នុហុត,មួយរយសែននុហុតថា១និន្នហុត,មួយរយសែននិន្នហុតថា១អក្ខោភិនី,មួយរយសែនអក្ខោភិនីថា១ពិន្ទុ,មួយរយសែនពិន្ទុថា១និរព្វុទ,មួយរយសែននិរព្វុទថា១អហហៈ,មួយរយសែនអហហៈថា១អពពៈ,មួយរយសែនអពពៈថា១អដដៈ,មួយរយសែនអដដៈថា១សោគន្ធិក,មួយរយសែនសោគន្ធិកថា១កុមុទ,មួយរយសែនកុមុទថា១បុណ្ឌរីក,មួយរយសែនបុណ្ឌរីកថា១បទុម,មួយរយសែនបទុមថា១កឋាន,មួយរយសែនកឋានថា១មហាកឋាន,មួយរយសែនមហាកឋានថា១អសង្ខេយ្យ។*

*អំពី១០០ដល់កោដិឲ្យយក១០គុណ អំពី១កោដិដល់អសង្ខេយ្យ ឲ្យយក១០០សែនគុណ* " ។

តាមឯកសារខាងលើនេះ យើងឃើញថា១អសង្ខេយ្យមានសូន្យ ១២៦ តែក៏បាត់ពីរឈ្មោះដែរ គឺ អព្វុទៈ និង ឧប្បលៈ។ បើបញ្ចូលឈ្មោះទាំងពីរនេះបន្ថែមក្នុងឯកសារហ្លួងពិភក្ដិជានី នោះ១អសង្ខេយ្យមានសូន្យគ្រប់ចំនួន ១៤០ ដោយត្រឹមត្រូវ។

ការប្រើប្រាស់របាប់ចំនួនបច្ចុប្បន្ននេះ គេនិយមប្រើត្រឹមលាន។ មានខ្លះប្រើដល់កោដិដែរ តែខុសន័យស្រឡះ ដោយយកកោដិ ជា១ពាន់លាន។ ខ្លះទៀតមិនសូវប្រើម៉ឺនសែនទេ តែប្រើត្រឹមពាន់ ឧទាហរណ៍ ៣៦០ ០០០ គេមិនថា "បីសែនប្រាំមួយម៉ឺន" ទេ គេថាបីរយហុកសិបពាន់វិញ។ ឯចំនួនធំៗទៅលើច្រើនទៀតគេនិយមប្រើតែ រយពាន់លានប៉ុណ្ណោះ ឧទាហរណ៍ (៤២ ១០០ ០០០ ០០០) សែសិបពីរពាន់មួយរយលាន, (៨៤០ ០០០ ០០០ ០០០ ០០០) ប្រាំបី រយសែសិបលានលាន។ល។

ជារួមប្រព័ន្ធបកតិសំខ្យាខ្មែរយើងមានច្រើនធំទូលំទូលាយណាស់ មិនដែលបានប្រើប្រាស់អស់ទេ រហូតដល់រលប់កប់បាត់ក្នុងប្រវត្តិកាល គួរឲ្យស្រណោះ។

លោក **យស់ អ៊ាង**

## សុ ចិ បុ លិ

បាលី (កិ.) ស្ដាប់, គិត, សួរ, សរសេរ ឬកត់ត្រា ។ អក្សរសង្ខេបអំពីពាក្យ សុត (ស្ដាប់), ចិន្ត (គិត), បុច្ឆ (សួរ), លិខ (សរសេរ,កត់,ចម្លង) ជាអង្គរបស់អ្នករៀន បានសេចក្ដីថា អ្នករៀនលុះតែប្រកបដោយអង្គ៤ គឺស្ដាប់ គិត សួរ សរសេរ ឬកត់ត្រា ចម្លង ទើបអាចនិងឡើងជាអ្នកចេះគ្រប់គ្រាន់បាន។ អង្គ៤នេះហៅថា សិក្សាចតុរាង្គ។

**សម្ដេចព្រះសង្ឃរាជ ជួន ណាត**

# ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ(២០១២)

(ត)

## VI-បញ្ជីឈ្មោះឃុំតាមស្រុក

| ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ | ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ | ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ |
|---|---|---|---|---|---|
| ១២ | **រាជធានីភ្នំពេញ** | ០៤ | ស្រុកគូលែនមាន ៦ឃុំ | | ២.ពោធិ៍ |
| | **មាន៩ ខណ្ឌនិង ៩៦សង្កាត់** | | ១.គូលែនត្បូង | | ៣.ប្រមេរុ |
| ១៣ | **ខេត្ត ព្រះវិហារ** | | ២.គូលែនជើង | | ៤.ព្រះឃ្លាំង |
| ០១ | ស្រុកជ័យសែនមាន៦ឃុំ | | ៣.ថ្មី | ០៨ | ក្រុងព្រះវិហារមាន២សង្កាត់ |
| | ១.ស្អាង | | ៤.ភ្នំពេញ | ១៤ | **ខេត្តព្រៃវែង** |
| | ២.តស៊ូ | | ៥.ភ្នំត្បែងពីរ | ០១ | ស្រុកបាភ្នំមាន ៩ឃុំ |
| | ៣.ខ្យង | | ៦.ស្រយង់ | | ១.បឹងព្រះ |
| | ៤.ច្រាច់ | ០៥ | ស្រុករវៀងមាន ១២ឃុំ | | ២.ជើងភ្នំ |
| | ៥.ធ្មា | | ១.របៀប | | ៣.ឈើកាច់ |
| | ៦.ពុទ្រា | | ២.រស្មី | | ៤.រក្សជ័យ |
| ០២ | ស្រុកឆែបមាន ៨ឃុំ | | ៣.រហ័ស | | ៥.រោងដំរី |
| | ១.ឆែបមួយ | | ៤.រុងរឿង | | ៦.ស្ដៅកោង |
| | ២.ឆែបពីរ | | ៥.រីករាយ | | ៧.ស្ពឺ ក |
| | ៣.សង្កែមួយ | | ៦.រួសរាន់ | | ៨.ស្ពឺ ខ |
| | ៤.សង្កែពីរ | | ៧.រតនៈ | | ៩.ថាយ |
| | ៥.ម្លូព្រៃមួយ | | ៨.រៀបរយ | ០២ | ស្រុកកំចាយមារមាន ៨ឃុំ |
| | ៦.ម្លូព្រៃពីរ | | ៩.រក្សា | | ១.ជាច |
| | ៧.កំពង់ស្រឡៅមួយ | | ១០.រំដោះ | | ២.ដូនកឹង |
| | ៨.កំពង់ស្រឡៅពីរ | | ១១.រមទម | | ៣.ក្រញូង |
| ០៣ | ស្រុកជាំក្សាន្តមាន ៨ឃុំ | | ១២.រមណីយ | | ៤.ក្របៅ |
| | ១.ជាំក្សាន្ត | ០៦ | ស្រុកសង្គមថ្មីមាន៥ឃុំ | | ៥.ស៊ាងឃ្វាង |
| | ២.ទឹកក្រហម | | ១.ចំរើន | | ៦.ស្មោងខាងជើង |
| | ៣.ព្រីងធំ | | ២.រអាង | | ៧.ស្មោងខាងត្បូង |
| | ៤.រំដោះស្រែ | | ៣.ភ្នំត្បែងមួយ | | ៨.ត្របែក |
| | ៥.យាង | | ៤.ស្ដៅ | ០៣ | ស្រុកកំពង់ត្របែកមាន១៣ឃុំ |
| | ៦.កន្ទួត | | ៥.រណសិរ្ស | | ១.អន្សោង |
| | ៧.មរកត | ០៧ | ស្រុកត្បែងមានជ័យមាន៤ឃុំ | | ២.ចាម |
| | ៨.ស្រអែម | | ១.ឈានមុខ | | ៣.ជាងដែក |

| ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ | ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ | ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ |
|---|---|---|---|---|---|
| | ៤.ជ្រៃ | | ៧.ព្រែកក្របៅ | | ១០.រំចេក |
| | ៥.កន្សោមអក | | ៨.ព្រែកសំបួរ | | ១១.សេនារាជឧត្ដម |
| | ៦.គោខ្ចក | | ៩.ឫស្សីស្រុក | ១០ | ក្រុងព្រៃវែងមាន៣សង្កាត់ |
| | ៧.កំពង់ត្របែក | | ១០.ស្វាយភ្លោះ | ១១ | ស្រុកកំពង់លាវមាន ៥ឃុំ |
| | ៨.ពាមមន្ទារ | ០៧ | ស្រុកពាមរក៍មាន ៨ឃុំ | | ១.បារាយណ៍ |
| | ៩.ប្រាសាទ | | ១.បាបោង | | ២.ព្រែកអន្ទះ |
| | ១០.ប្រជាគុ | | ២.បន្លិចប្រាសាទ | | ៣.ព្រែកជ្រៃ |
| | ១១.ព្រៃឈរ | | ៣.អ្នកលឿង | | ៤.ព្រែកកន្លោង |
| | ១២.ព្រៃពោន | | ៤.ពាមមានជ័យ | | ៥.តាកោ |
| | ១៣.ថ្កូវ | | ៥.ពាមរក៍ | ១២ | ស្រុកស៊ីធរកណ្ដាលមាន១១ឃុំ |
| ០៤ | ស្រុកកញ្ជ្រៀចមាន ៨ឃុំ | | ៦.ព្រែកខ្សាយ ក | | ១.អំពិលក្រៅ |
| | ១.ចុងអំពិល | | ៧.ព្រែកខ្សាយ ខ | | ២.ជ្រៃឃុំ |
| | ២.កញ្ជ្រៀច | | ៨.ព្រែកណ្ដៀង | | ៣.ល្វេ |
| | ៣.ក្ដឿងរាយ | ០៨ | ស្រុកពារាំងមាន ១១ឃុំ | | ៤.ព្នៅទី១ |
| | ៤.គោកគង់កើត | | ១.កំពង់ពពិល | | ៥.ព្នៅទី២ |
| | ៥.គោកគង់លិច | | ២.កញ្ចំ | | ៦.ពោធិទី |
| | ៦.ព្រាល | | ៣.កំពង់ប្រាំង | | ៧.ព្រែកចង្ក្រាន |
| | ៧.ថ្មពូន | | ៤.កំពង់ឫស្សី | | ៨.ព្រៃដើមថ្នឹង |
| | ៨.ត្នោត | | ៥.មេសរប្រចាន់ | | ៩.ព្រៃទឹង |
| ០៥ | ស្រុកមេសាងមាន ៨ឃុំ | | ៦.ព្រែកតាសរ | | ១០.រំលេច |
| | ១.អង្គរសរ | | ៧.ព្រៃព្នៅ | | ១១.ឫស្សីសាញ់ |
| | ២.ច្រេស | | ៨.ព្រៃស្នៀត | ១៣ | ស្រុកស្វាយអន្ទរមាន ១១ឃុំ |
| | ៣.ជីផុច | | ៩.ព្រៃស្រឡិត | | ១.អង្គរទ្រេត |
| | ៤.ព្រៃឃ្នេស | | ១០.រាប | | ២.ជាខ្លាង |
| | ៥.ព្រៃរំដេង | | ១១.រកា | | ៣.ជ្រៃ |
| | ៦.ព្រៃទទឹង | ០៩ | ស្រុកព្រះស្ដេចមាន ១១ឃុំ | | ៤.ដំរីពួន |
| | ៧.ស្វាយប្រជុំ | | ១.អង្គររាជ្យ | | ៥.មេបុណ្យ |
| | ៨.ត្រពាំងស្រែ | | ២.បន្ទាយចក្រី | | ៦.ពានរោង |
| ០៦ | ស្រុកពាមជរមាន ១០ឃុំ | | ៣.បឹងដោល | | ៧.ពពឺស |
| | ១.អង្គរអង្គ | | ៤.ដៃកំពក | | ៨.ព្រៃខ្លា |
| | ២.កំពង់ប្រាសាទ | | ៥.កំពង់សឹង | | ៩.សំរោង |
| | ៣.កោះចេក | | ៦.ក្រាំងស្វាយ | | ១០.ស្វាយអន្ទរ |
| | ៤.កោះរកា | | ៧.ល្វា | | ១១.ទឹកថ្លា |
| | ៥.កោះសំពៅ | | ៨.ព្រះស្ដេច | | |
| | ៦.ក្រាំងតាយ៉ង | | ៩.រាធរ | | |

| ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ | ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ | ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ |
|---|---|---|---|---|---|
| ១៤ | **ខេត្ត ពោធិ៍សាត់** | | ៧.ស្យា | | ៤.ព្រងិល |
| ០១ | ស្រុកបាកានមាន ១០ឃុំ | | ៨.វាល | | ៥.រកាត |
| | ១.បឹងបត់កណ្ដាល | | ៩.កោះជុំ | | ៦.សន្ទ្រែ |
| | ២.បឹងខ្នារ | ០៣ | ស្រុកក្រគរមាន ១១ឃុំ | | ៧.សំរោង |
| | ៣.ខ្នារទទឹង | | ១.អន្លង់ត្នោត | ០៥ | ក្រុងពោធិ៍សាត់មាន ៧សង្កាត់ |
| | ៤.មេទឹក | | ២.អន្សាចំបក់ | ០៦ | ស្រុកវាលវែងមាន ៥ឃុំ |
| | ៥.អូរតាប៉ោង | | ៣.បឹងកន្ទួត | | ១.អូរសោម |
| | ៦.រំលេច | | ៤.ឈើតុំ | | ២.ក្រពើពីរ |
| | ៧.ស្នាមព្រះ | | ៥.កំពង់លួង | | ៣.អន្លង់រាប |
| | ៨.ស្វាយដូនកែវ | | ៦.កំពង់ពោធិ៍ | | ៤.ប្រម៉ោយ |
| | ៩.តាលោ | | ៧.ក្បាលត្រាច | | ៥.ថ្មដា |
| | ១០.ត្រពាំងជង | | ៨.អូរសណ្ដាន់ | | |
| ០២ | ស្រុកកណ្ដៀងមាន ១០ឃុំ | | ៩.ស្នាអន្សា | | |
| | ១.អន្លង់វិល | | ១០.ស្វាយ ស | | |
| | ២.កណ្ដៀង | | ១១.ត្នោតជុំ | | |
| | ៣.កញ្ជរ | ០៤ | ស្រុកភ្នំក្រវាញមាន ៧ឃុំ | | |
| | ៤.រាំងទិល | | ១.បាក់ចិញ្ចៀន | | |
| | ៥.ស្រែស្តុក | | ២.លាជ | | |
| | ៦.ស្វាយលួង | | ៣.ផ្ទះរុង | | |

ទីក្រុង La Rincodana មានទីតាំងនៅក្នុងប្រទេសប៉េរូ ជាតំបន់ជីករ៉ែមាសរ៉ែយចំណាស់មួយ។ នៅក្នុងទីក្រុងនេះ មានប្រជាជនរស់នៅប្រមាណជា ៥០ ០០០ នាក់ ជាទីក្រុងដែលមានទីតាំងស្ថិតនៅលើភ្នំ ក្នុងកម្រិតកម្ពស់ ៥ ១០០ម៉ែត្រ ដែលបច្ចុប្បន្នត្រូវបានទទួលតំណែងជា ទីក្រុងដែលខ្ពស់ជាងគេបំផុតនៅលើពិភពលោក។

**អ៊ិនធើណែត**

# ដំណឹងមរណទាព

គណៈកម្មាធិការកណ្តាលសមាគមបុគ្គលិកសិក្សាខ្មែរមានទុក្ខក្រៀមក្រំដោយ ឯកឧត្តម អ៊ុន ថៅរ អគ្គលេខាធិការគណៈកម្មាធិការកណ្តាលសមាគមបុគ្គលិកសិក្សាខ្មែរ បានទទួលមរណទាព នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១៥ វេលាម៉ោង ៧:៣០ នាទីយប់ ក្នុងជន្មាយុ ៦៧ឆ្នាំ ដោយរោគាពាធ។

គណៈកម្មាធិការកណ្តាលសមាគមបុគ្គលិកសិក្សាខ្មែរសូមចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសព ព្រមទាំងសូមឱ្យវិញ្ញាណក្ខន្ធឯកឧត្តមបានទៅកាន់សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ
គណៈកម្មាធិការកណ្តាល
លេខ: ២១/១៤ គ.ក

# សេចក្តីជូនដំណឹងមរណភាពប្រចាំខែសីហា ឆ្នាំ២០១៤

តាងនាមសមាគមបុគ្គលិកសិក្សាខ្មែរទាំងមូល គណៈកម្មាធិការកណ្តាលនៃ ស.ប.ស.ខ

សូមសម្តែងក្តីសោកស្តាយជាទីបំផុតចំពោះការបាត់បង់ជីវិតមិត្តយើង និងគ្រួសារ

ហើយសូមចូលរួមកាន់ទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខណ្ឌ | អង្គភាពបម្រើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | | ខ.មរណៈភាពគ្រូស្រករ | សពទី | | | |
| 1 | យិន សារុន | ៦១ | ប | គ្រូបឋម | បសាលាបឋមអង្គលំទង. ស្រុកគង់ពិសី ខេត្តកំពង់ស្ពឺ | ១៥២០១៤/០៥/ | រោគាពាធ | ០២៨៨កស្ព | ៩៧៩១ |
| 2 | ធួន កាន | ៤៤ | ស | គ្រូបឋម | បម្រុំជើង. ច្បារមន ខេត្តកំពង់ស្ពឺ | ២៥២០១៤/០៥/ | រោគាពាធ | ១០៧៥កស្ព | ៩៧៩២ |
| 3 | គីម ទិត | ៣៨ | ប | គ្រូកំមូលដ្ឋាន. | វិបរសេដ្ឋ. បរសេដ្ឋ ខេត្តកំពង់ស្ពឺ | ២១២០១៤/០៥/ | រោគាពាធ | ៤០០៦កស្ព | ៩៧៩៣ |
| 4 | ខៀវ គ្រី | ៨៧ | ប | បឋម | និវត្ត.១បឋមសិក្សាព្រែកក្របៅ.ពាមជរ ខេត្តព្រៃវែង | ២៣២០១៤/០៤/ | ជរាពាធ | ៧៣៥០ ៣វ | ៩៧៩៤ |
| 5 | គីម ស៊ីម | ៦៨ | ប | បឋម | និវត្តកំចាយមារ.បឋមសិក្សាព្រែកក្របៅចាស់. ខេត្តព្រៃវែង | ០៤២០១៤-០៥- | ជរាពាធ | ២៧៧៦ ៣វ | ៩៧៩៥ |
| 6 | ឡឹក ណាត់ | ៦៥ | ប | មូលដ្ឋាន | និវត្តវិទ្យាល័យ. ហស តាគោកព្រះស្តេច ខេត្តព្រៃវែង . | ២៦០/3/២០១៤ | រោគាពាធ | ៥៩៣ ៣វ | ៩៧៩៦ |
| 7 | ប្រាក់ វឿន | ៣០ | ប | មូលដ្ឋាន | វិទ្យាល័យជាចកំចាយមារ. ខេត្តព្រៃវែង | ០៤២០១៤-០៥- | គ្រោះថ្នាក់ចរាចរណ៍ | ៩៦៤០ ៣វ | ៩៧៩៧ |
| 8 | យឹះ វិសេស | ៤២ | ប | មក.ទ. | វិទ្យាល័យអង្គរក្រុងសៀមរាប- ខេត្តសៀមរាប | ២៦២០១៤/០៤/ | រោគាពាធ | ១០៨៧សរ. | ៩៧៩៨ |
| 9 | សូ ឈុនប៉ូ | ៦១ | ប | និវត្ត | បឋម ហស. ក្រុងកែប ខេត្តកែប | ២៦២០១៤/០៦/ | ដំបៅក្រពះ | ០១៤ ខក. | ៩៧៩៩ |
| 10 | ឡឹ សាមុត | ៤៦ | ប | បឋម | បឋម ក្ងោក ស្រុកថាឡា បរីវ៉ាត់ ខេត្តស្ទឹងត្រែង | ៣១២០១៤/០៥/ | រោគាពាធ | ០៣៩៣ សត. | ៩៨០០ |
| 11 | គឿន ភារី | ៣១ | ប | បឋម | បឋម ចកតូច មោងឫស្សី ខេត្ត បាត់ដំបង | ២៣២០១៤/០៥/ | ចោរប្លន់ | ១០៣៤៦ បប. | ៩៨០១ |
| 12 | ឈូក យ៉ុង | ៧១ | ប | បឋម | និវត្តនជ ស្រុក ថ្មគោល ខេត្ត បាត់ដំបង | ២៤២០១៤/០៥/ | ជរាពាធ | ១៧៣៤បប. | ៩៨០២ |
| 13 | ឡាច ទុំ | ៧៦ | ប | បឋម | និវត្តជន ស្រុក ថ្មគោល ខេត្ត បាត់ដំបង | ០២២០១៤-០៦- | ជរាពាធ | ១៦៦៥បប. | ៩៨០៣ |
| 14 | ធឹង សារឿន | ៥៨ | ប | បឋម | ការិ.អប់រំ ស្រុកសំពៅលូន ខេត្ត បាត់ដំបង | ០៣-០៦-២០១៤ | ដាច់សរសៃឈាមខួរក្បាល | ៥៩៧៩ប.ប | ៩៨០៤ |
| 15 | អ៊ូ សៀក | ៦៩ | ប | បឋម | និវត្តជន ក្រុង បាត់ដំបង ខេត្ត បាត់ដំបង | ០៨-០៦-២០១៤ | ជរាពាធ | ៣០២៤ប.ប | ៩៨០៥ |
| 16 | គឹម សារ៉ាន | ៣៩ | ប | បឋម | បឋមអូរអន្លក់ ស្រុកកំរៀង ខេត្ត បាត់ដំបង | ១១-០៦-២០១៤ | រលាកតម្រងនោម | ៦៥៥៣ប.ប | ៩៨០៦ |
| 17 | យន់ សុភ័ក្រ្ត | ៤៣ | ប | បឋម | បឋម បាក់អំរែកស្រុកឯកភ្នំ ខេត្ត បាត់ដំបង | ១៩/០៦/២០១៤ | ជំងឺសរសៃប្រសាទ | ៤៣៧១ប.ប | ៩៨០៧ |
| 18 | ស៊ុន រ៉ែម | ៤៥ | ស | បឋម | បឋម ឆ្កែខាំប្រើស ស្រុករុក្ខគីរី ខេត្ត បាត់ដំបង | ២២/០៦/២០១៤ | ដាច់សរសៃឈាមខួរក្បាល | ៧៨២៨ប.ប | ៩៨០៨ |
| 19 | សៅ យ៉ុង | ៥៩ | ប | បឋម | បឋម ត្រើយកោះ ក្រុងកំពត ខេត្តកំពត | ០៣-០៧-២០១៤ | រោគាពាធ | ២៨២៧ក.ព | ៩៨០៩ |
| 20 | ង៉ែត សាមេត | ៤៨ | ស | បឋម | បឋម អង្គឈូក ស្រុកឈូក ខេត្តកំពត | ២១/០៦/២០១៤ | រោគាពាធ | ៣៤៩៤ក.ព | ៩៨១០ |
| 21 | កឹម នាក់ | ៧០ | ប | បឋម | និវត្តជន បឋម ខ្វាវ ស្រុកអង្គរជ័យ ខេត្តកំពត | ១៨/០៦/២០១៤ | រោគាពាធ | ២០៧៧ក.ព | ៩៨១១ |
| 22 | ឆាយ ម៉េងស៊ិន | ៦៩ | ប | បឋម | និវត្តជន បឋម បរិវាស ស្រុកបន្ទាយមាស ខេត្តកំពត | ០៤-០៦-២០១៤ | រោគាពាធ | ៣២៤៩ក.ព | ៩៨១២ |
| 23 | ពេជ្រ ឈុន | ៦៩ | ប | គ្រូ | និវត្តជន ស្រុក រមាសហែក ខេត្តស្វាយរៀង | ១៤/០៥/២០១៤ | រោគាពាធ | ១៤៩៣ស្វ.រ | ៩៨១៣ |
| 24 | សរ ស៊ាន | ៥៩ | ប | បឋម | បឋម ហ.ស កោះគោ ស្រុកចន្ទ្រា ខេត្តស្វាយរៀង | ២៣/០៦/២០១៤ | រោគាពាធ | ៨១៩ ស្វ.រ | ៩៨១៤ |
| 25 | ថោង សារឿន | ៥២ | ប | គ្រូ | និវត្តជន ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង | ០៥-០៧-២០១៤ | ជម្ងឺរបេង | ២៥២៨ស្វ.រ | ៩៨១៥ |
| 26 | ប្រាជ្ញ គយ | ៧២ | ប | គ្រូ | និវត្តជន ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង | ០៣-០៧-២០១៤ | លើសឈាម | ២៦២៦ស្វ.រ | ៩៨១៦ |
| 27 | សំ សាក់ | ៧៤ | ប | គ្រូ | និវត្តជន ក្រុង ស្វាយរៀង ខេត្តស្វាយរៀង | ១១-០៧-២០១៤ | គ្រោះថ្នាក់ចរាចរណ៍ | ១៨៩០ ស្វ.រ | ៩៨១៧ |
| 28 |ឃួន ធុន | ៦០ | ប | បឋម | បឋមទួល សាលា ស្រុករំដួល ខេត្តស្វាយរឿង | ២២/០៥/២០១៤ | ទឹកនោមផ្អែម | ២៩៥០ស្វ.រ | ៩៨១៨ |
| 29 | ប៉ុក ម៉ុន | ៦២ | ប | បឋម | និវត្តជន ស្រុកកៀនស្វាយ ខេត្តកណ្តាល | ១៤/០៥/២០១៤ | ជម្ងឺក្រពះ | ៧៣៤៥ក.ណ | ៩៨១៩ |
| 30 | ភឹម សារ៉ាន់ | ៥៥ | ស | បឋម | បឋម.ជង្រុក ស្រុកអង្គស្នួល ខេត្តកណ្តាល | ១៩/០៤/២០១៤ | រោគាពាធ | ៤៩២៨ក.ណ | ៩៨២០ |
| 31 | បេង ឡុង | ៦៥ | ប | បឋម | និវត្តជន ស្រុកស្អាង ខេត្តកណ្តាល | ៣១/០៥/២០១៤ | រោគាពាធ | ៥៩៤១ក.ណ | ៩៨២១ |
| 32 | ហែម ង៉ិល | ៦៨ | ប | បឋម | និវត្តជន ស្រុកល្វាឯម ខេត្តកណ្តាល | ២៦/០៥/២០១៤ | រោគាពាធ | ២៤៥០ក.ណ | ៩៨២២ |
| 33 | ឡៅ សារឿន | ៦៧ | ប | បឋម | និវត្តជន ស្រុកស្អាង ខេត្តកណ្តាល | ០៧-០៦-២០១៤ | រោគាពាធ | ៦១៨៣ក.ណ | ៩៨២៣ |
| 34 | អ៊ូ ហ៊ីម | ៦៧ | ប | បឋម | និវត្តជន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល | ១៨/០៦/២០១៤ | ជម្ងឺសួត | ៤៤៤១ ក.ណ | ៩៨២៤ |
| 35 | ទឹម សុខ | ៥៩ | ប | មបក | អនុវិទ្យាល័យបារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ | ១៦/០៤/២០១៤ | ជរាពាធ | ១២៩ ត.ក | ៩៨២៥ |
| 36 | តាត់ ភិន | ៨០ | ប | គ្រូ | និវត្តជន ស្រុកត្រាំកក់ ខេត្តតាកែវ | ២៥/០៤/២០១៤ | ជរាពាធ | ៥៧៦៧ ត.ក | ៩៨២៦ |
| 37 | ឃុត ណូវ | ៦៨ | ប | គ្រូ | និវត្តជន ស្រុកព្រៃកប្បាស ខេត្តតាកែវ | ១៥/០៥/២០១៤ | ជរាពាធ | ៥២១៤ ត.ក | ៩៨២៧ |
| 38 | គឹម យន់ | ៧៦ | ប | គ្រូ | និវត្តជន ស្រុកបាទី ខេត្តតាកែវ | ២៩/០៥/២០១៤ | ជរាពាធ | ៥៣៥៨ ត.ក | ៩៨២៨ |
| 39 | លៀង នាង | ៧០ | ប | គ្រូ | និវត្តជន ស្រុកបាទី ខេត្តតាកែវ | ២១/០៥/២០១៤ | ជរាពាធ | ១៣៧៨ត.ក | ៩៨២៩ |
| 40 | អង ណុល | ៥០ | ប | បឋម | បឋមបន្ទាយរី ស្រុកបាទី ខេត្តតាកែវ | ២៥/០៥/២០១៤ | ជរាពាធ | ១៤៣២ត.ក | ៩៨៣០ |
| 41 | យឹម ណារិទ្ធ | ៦៧ | ស | គ្រូបឋម | និវត្តជន បឋមព្រែកលីវ កងមាស កំពង់ចាម | ០៩-០៦-២០១៤ | លើសឈាម | ៨២២៦ក.ច | ៩៨៣១ |
| 42 | រៀម ម៉េង | ៦៨ | ប | គ្រូបឋម | និវត្តជន បឋម តាគោហ៊ើ កងមាស កំពង់ចាម | ១៤/០៦/២០១៤ | រោគាពាធ | ៨៣៣៤ក.ច | ៩៨៣២ |
| 43 | អ៊ុច ស៊ីន | ៧២ | ប | គ្រូបឋម | និវត្តជន បឋមសំរោងបុរី ត្បូងឃ្មុំ ត្បូងឃ្មុំ | ១៧/០៧/២០១៤ | រោគាពាធ | ៩៥៦៦ក.ច | ៩៨៣៣ |
| 44 | ពាញ ហេង | ៧៥ | ស | គ្រូបឋម | និវត្តជន វិ.ព្រះសីហនុ កំពង់ចាម កំពង់ចាម | ២១/០៦/២០១៤ | ទឹកនោមផ្អែម | ៧២២ក.ច | ៩៨៣៤ |
| 45 | ទៀង គាន | ៨១ | ប | គ្រូបឋម | និវត្តជន បឋម ល្ងៀង ត្បូងឃ្មុំ ត្បូងឃ្មុំ | ២០/០៦/២០១៤ | ជរាពាធ | ៩៧២២ក.ច | ៩៨៣៥ |
| 46 | ប៊ូ ប៉ា | ៦៦ | ប | គ្រូបឋម | និវត្តជន បឋម ទួលស្នួល ក្រូចឆ្មារ ត្បូងឃ្មុំ | ២៩/០៦/២០១៤ | ទឹកនោមផ្អែម | ៦៣៤៧ក.ច | ៩៨៣៦ |
| 47 | គង់ ចំរើន | ៦១ | ប | គ្រូបឋម | និវត្តជន បឋមប៊ុនរ៉ានីហ៊ុន សែនមេមង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ | ១៨/០៦/២០១៤ | រោគាពាធ | ៤៣៨ ក.ច | ៩៨៣៧ |
| 48 | វង់ សុផល | ៤២ | ប | បឋម | បឋម រាំងមួន ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ | ០៩-០៧-២០១៤ | ខ្សែភ្លើងឆក់ | ២០៨៦ប.ជ | ៩៨៣៨ |
| 49 | ចាន់ សុវណ្ណ | ៦១ | ប | ម.ប.ភ | និវត្តជន វិទ្យាល័យកូប ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ | ១៣/០៧/២០១៤ | លើសឈាម | ២១០៦ប.ជ | ៩៨៣៩ |
| 50 | ម៉ឹង តិចគង់ | ៧៦ | ប | គ្រូ | និវត្តជន ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ | ៣០/០៥/២០១៤ | រោគាពាធ | ៤៥៨ ភ.ព | ៩៨៤០ |
| 51 | ញឹក សាម៉ុន | ៧១ | ប | គ្រូ | និវត្តជន វិទ្យាល័យឥន្ទ្រទេវី ខណ្ឌសែនសុខ រាជធានីភ្នំពេញ | ៣០/០៥/២០១៤ | រោគាពាធ | ២៤៥៣ភ.ព | ៩៨៤១ |
| 52 | ពួន ស៊ីម | ៨៣ | ប | គ្រូ | និវត្តជន ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ | ០៣-០៧-២០១៤ | រោគាពាធ | ៧២៩ ភ.ព | ៩៨៤២ |




ភ្នំពេញ : រថយន្តឈ្នួលសម្រាប់ដឹកអ្នកដំណើរ